រដ្ឋសភា
ចូល លេខ ៣៣៤០
ថ្ងៃទី២៣/១១ ឆ្នាំ២០២០ ម៉ោង
បញ្ជូនទៅ

# ព្រះរាជក្រម

នស/រកម/១១២០/០៣៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់

## ស្តីពី

# ការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងធានាការគ្រប់គ្រងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណៃនិងល្បែងពាណិជ្ជកម្ម ដើម្បីរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច លើកកម្ពស់វិស័យទេសចរណ៍ បង្កើតការងារ ប្រមូលចំណូល រក្សាសុវត្ថិភាពនិងសន្តិសុខសង្គម ដោយកំណត់សមត្ថកិច្ច វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណៃនិងល្បែងពាណិជ្ជកម្ម សិទ្ធិនិងកាតព្វកិច្ចរបស់រូបវន្តបុគ្គលនិងនីតិបុគ្គលក្នុងការធ្វើប្រតិបត្តិការដោយផ្ទាល់ឬចូលរួមនៅក្នុងល្បែងពាណិជ្ជកម្មនិងកំណត់សិទ្ធិជាម្ចាស់លើមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណៃនិងលើគ្រឹះស្ថានល្បែងពាណិជ្ជកម្មព្រមទាំងបង្កើតស្តង់ដាមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណៃនិងល្បែងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណៃនិងល្បែងពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចកំណត់នៅក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

# ជំពូកទី២
## គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា(គ.ល.ក.)
### ផ្នែកទី១
### សមត្ថកិច្ចរបស់ គ.ល.ក.

**មាត្រា៤ .-**

ត្រូវបានបង្កើតគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា សរសេរជាអក្សរកាត់ គ.ល.ក. ដែលមានសមត្ថកិច្ចក្នុងការស្នើឡើងនូវគោលនយោបាយ ចេញបទប្បញ្ញត្តិ គ្រប់គ្រង ត្រួតពិនិត្យ ផ្តល់អាជ្ញាបណ្ណ ប្រមូលចំណូល និងចាត់វិធានការចាំបាច់ទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណៃនិងល្បែងពាណិជ្ជកម្ម។

**មាត្រា៥ .-**

គ.ល.ក. មានសមាសភាព ចំនួន១១(ដប់មួយ)រូប ដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ — ប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១(មួយ)រូប — អនុប្រធាន
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១(មួយ)រូប — សមាជិក
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១(មួយ)រូប — សមាជិក

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១(មួយ)រូប សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១(មួយ)រូប សមាជិក
- រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១(មួយ)រូប សមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១(មួយ)រូប សមាជិក
- អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ សមាជិក
- អគ្គលេខាធិការនៃគ.ល.ក. សមាជិក
- អគ្គលេខាធិការរងនៃគ.ល.ក. សមាជិក

សមាសភាពជាក់ស្តែងនៃគ.ល.ក. ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធានគ.ល.ក.។

**មាត្រា៦ ._**

គ.ល.ក. មានមុខងារនិងភារកិច្ចដូចខាងក្រោម៖

ក. ជាបញ្ញត្តិករនិងនិយ័តករលើវិស័យមណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណនិងល្បែងពាណិជ្ជកម្ម។

ខ. ស្នើឡើងនូវគោលនយោបាយអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណនិងល្បែងពាណិជ្ជកម្ម។

គ. ផ្តល់អាជ្ញាបណ្ណកាស៊ីណូ អាជ្ញាបណ្ណល្បែងភ្នាល់ អាជ្ញាបណ្ណល្បែងផ្សងសំណាង អាជ្ញាបណ្ណល្បែងពាណិជ្ជកម្មដទៃទៀត អាជ្ញាបណ្ណបុគ្គលិកពិសេស អាជ្ញាបណ្ណអ្នកជំរុញល្បែងពាណិជ្ជកម្ម និងអាជ្ញាបណ្ណអ្នកផលិត អ្នកដំឡើង អ្នកនាំចូល អ្នកលក់ ឬអ្នកចែកចាយឧបករណ៍ និងកម្មវិធីល្បែង រួមទាំងការកែប្រែ ការពន្យារ ការផ្អាក ការបិទដំណើរការ ការព្យួរ ការដកហូត និងការប្រគល់វិញនូវអាជ្ញាបណ្ណទាំងនោះ។

ឃ. អនុម័តលើប្រភេទល្បែងដែលអនុញ្ញាតឱ្យដំណើរការនៅក្នុងកាស៊ីណូឬនៅក្នុងគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត រួមទាំងរបៀបលេងនិងវិធានល្បែង។

ង. ចេញសេចក្តីណែនាំដល់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម អំពីប្រភេទជាក់លាក់នៃល្បែងណាមួយដែលមិនត្រូវបានអនុញ្ញាតឱ្យដំណើរការនៅក្នុងគ្រឹះស្ថានល្បែងពាណិជ្ជកម្ម។

ច. អនុម័តលើស្តង់ដានៃការត្រួតពិនិត្យផ្ទៃក្នុង នីតិវិធីរដ្ឋបាល និងគោលនយោបាយគណនេយ្យសម្រាប់កាស៊ីណូនិងគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត។

ឆ. ដាក់ចេញនូវវិធានការដើម្បីការពារជនងាយរងគ្រោះ រួមទាំងកុមារ ពីល្បែង និងការទប់ស្កាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មពាក់ព័ន្ធនឹងល្បែងពាណិជ្ជកម្ម។

ជ. ពិនិត្យនិងសម្រេចលើបណ្តឹងជំទាស់ពាក់ព័ន្ធនឹងប្រតិបត្តិការល្បែងក្នុងកម្រិតដែលអនុញ្ញាតដោយច្បាប់នេះ។

**មាត្រា៧ ._**

អនុប្រធាននិងសមាជិកគ.ល.ក. មានអាណត្តិ៥(ប្រាំ)ឆ្នាំ ហើយអាចត្រូវបានតែងតាំងឡើងវិញ លើកលែងតែសមាជិកដែលជាអគ្គលេខាធិការនិងអគ្គលេខាធិការរង មិនត្រូវបានកំណត់អាណត្តិទេ។

អនុប្រធាននិងសមាជិកគ.ល.ក.ណាម្នាក់ អាចត្រូវបាត់បង់ពីមុខតំណែងក្នុងករណីដូចខាងក្រោម៖

ក. ការស្នើសុំលាលែងពីការងារ។

ខ. ការបាត់បង់សមត្ថភាពក្នុងការបំពេញការងារ។

គ. ការបាត់បង់លក្ខណៈសម្បត្តិ ដូចមានកំណត់ក្នុងមាត្រា៥នៃច្បាប់នេះ។

ឃ. ការបញ្ឈប់ពីមុខតំណែងតាមការសម្រេចរបស់គ.ល.ក. ដោយសំឡេង២ភាគ៣(ពីរភាគបី) នៃចំនួនសមាជិកគ.ល.ក. ទាំងមូល ដោយសារការប្រព្រឹត្តកំហុសនៅក្នុងតួនាទីរបស់ខ្លួន។

ង. ការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ។

អនុប្រធាននិងសមាជិកគ.ល.ក.ណាម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ នឹងត្រូវព្យួរការងារជាបណ្តោះអាសន្ន។

ការជំនួស អនុប្រធាន និងសមាជិកគ.ល.ក.ដែលបាត់បង់សមាជិកភាព ត្រូវអនុវត្តដូចគ្នានឹងនីតិវិធីនៃការតែងតាំង។

**មាត្រា៨ ._**

គ.ល.ក.ត្រូវរៀបចំកិច្ចប្រជុំជាទៀងរាល់ឆមាស។ គ.ល.ក.អាចបើកកិច្ចប្រជុំវិសាមញ្ញបានគ្រប់ពេលវេលាអាស្រ័យលើការចាំបាច់តាមការអញ្ជើញរបស់ប្រធានឬតាមសំណើរបស់អគ្គលេខាធិការនៃគ.ល.ក. ឬតាមសំណើពីសមាជិកដែលមានចំនួនយ៉ាងតិច១ភាគ៣(មួយភាគបី)នៃចំនួនសមាជិកទាំងមូល។ កិច្ចប្រជុំ គ.ល.ក.អាចប្រព្រឹត្តទៅបាន លុះត្រាតែមានកូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងមូល។ សមាសភាពនៃគ.ល.ក. ដែលអវត្តមាន មិនអាចត្រូវជំនួសបានទេ។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួន ការប្រជុំត្រូវលើកទៅកាលបរិច្ឆេទក្រោយទៀតតាមការកំណត់របស់ប្រធាន ហើយត្រូវពិភាក្សាឡើងវិញលើរបៀបវារៈដដែល។ សេចក្តីសម្រេចរបស់គ.ល.ក.អាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានត្រូវមានឧត្តមានុភាព។

លាភការរបស់ប្រធាន អនុប្រធាន និងសមាជិកនៃគ.ល.ក. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើដែលត្រូវបានអនុម័តនៃកិច្ចប្រជុំពេញអង្គរបស់គ.ល.ក.។

**មាត្រា៩ ._**

គ.ល.ក. ត្រូវមានរូបសញ្ញានិងត្រាសម្រាប់ប្រើប្រាស់ក្នុងដំណើរការការងាររបស់ខ្លួន។

## ផ្នែកទី២
## ដែនសមត្ថកិច្ចរបស់ គ.ល.ក.

**មាត្រា១០ ._**

គ.ល.ក. អាចចេញលិខិតបទដ្ឋានគតិយុត្តនានា រួមមានប្រកាស សេចក្តីសម្រេច និងវិធាននានាដែលពាក់ព័ន្ធនឹង៖

ក. បែបបទនិងទម្រង់នៃពាក្យស្នើសុំការអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍។

ខ. បែបបទនិងទម្រង់ នៃពាក្យស្នើសុំអាជ្ញាបណ្ណគ្រប់ប្រភេទ។

គ. ការកំណត់នូវសេវានិងស្តង់ដាអប្បបរមាដែលមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍និងគ្រឹះស្ថានល្បែងពាណិជ្ជកម្មនីមួយៗត្រូវមាន ដូចជាបរិវេណលេងល្បែង សណ្ឋាគារ ភោជនីយដ្ឋាន និង/ឬផ្សារទំនើបជាដើម

ឃ. ប្រភេទនិងវិធាននៃល្បែង។

ង. ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គណនេយ្យ និងសវនកម្ម។

ច. ការផ្សព្វផ្សាយល្បែងពាណិជ្ជកម្ម។

ឆ. ការគ្រប់គ្រង ការផ្តល់ឥណទានចំពោះភ្ញៀវល្បែងដោយប្រតិបត្តិករកាស៊ីណូ និងអ្នកជំរុញល្បែងពាណិជ្ជកម្ម។

ជ. បទប្បញ្ញត្តិដទៃទៀតដែលមិនផ្ទុយពីច្បាប់នេះ។

**មាត្រា១១ ._**

គ.ល.ក. មានសិទ្ធិបន្ថែមដូចខាងក្រោម៖

ក. ចាត់ចែងការស៊ើបអង្កេតលើករណីមានបណ្តឹងតវ៉ាទាក់ទងនឹងការបំពានលើបញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិដទៃទៀតពាក់ព័ន្ធនឹងច្បាប់នេះ។

ខ. តម្រូវឱ្យប្រតិបត្តិករល្បែងពាណិជ្ជកម្ម កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ កម្មសិទ្ធិករកាស៊ីណូ និងភាគីពាក់ព័ន្ធ ផ្តល់ឯកសារ ឬព័ត៌មានតាមការចាំបាច់។

គ. ចុះធ្វើការត្រួតពិនិត្យដល់ទីកន្លែង រួមមានកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត កន្លែងផលិត លក់ ឬបែងចែកឧបករណ៍ល្បែង និងកម្មវិធីល្បែង តាមការចាំបាច់ដោយមិនបាច់ជូនដំណឹងជាមុន។

ឃ. ចុះកិច្ចសន្យា ឬអនុស្សរណៈនៃការយោគយល់គ្នាជាមួយស្ថាប័នរាជរដ្ឋាភិបាល ឬ/និង ស្ថាប័នអន្តរជាតិ សម្រាប់គោលដៅនៃការបែងចែកព័ត៌មាន កិច្ចសហប្រតិបត្តិការបច្ចេកទេស ការស៊ើបអង្កេតរួម និងការបំពេញភារកិច្ចដទៃទៀតអនុលោមតាមច្បាប់នេះ។

ង. កំណត់សោហ៊ុយទម្រង់ការនិងកម្រៃផ្សេងៗ ដែលទាក់ទងនឹងការគ្រប់គ្រងនិងត្រួតពិនិត្យល្បែងពាណិជ្ជកម្ម រួមទាំងកម្រៃជើងសាសម្រាប់ទូទាត់ដល់អ្នកជំរុញល្បែងពាណិជ្ជកម្ម។

ច. សិទ្ធិអំណាចផ្សេងៗទៀត ដែលចាំបាច់សម្រាប់ធានាដល់ការអនុវត្តច្បាប់នេះ ប្រកបដោយប្រសិទ្ធភាព។

**មាត្រា១២ ._**

គ.ល.ក. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប និងអគ្គលេខាធិការរង១(មួយ)រូប។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវលើកសំណើរួមគ្នា សុំតែងតាំងអគ្គលេខាធិការ និងអគ្គលេខាធិការរងនៃ គ.ល.ក. ជូននាយករដ្ឋមន្ត្រី។

អគ្គលេខាធិការដែលជាតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបន្ទុកគ្រប់គ្រងរួមនិងគ្រប់គ្រងការប្រមូលចំណូលកាតព្វកិច្ចពីល្បែង កម្រៃ សោហ៊ុយ និងចំណូលផ្សេងៗទៀត ដែលកំណត់ដោយច្បាប់នេះ។

អគ្គលេខាធិការរងដែលជាតំណាងក្រសួងមហាផ្ទៃ ទទួលបន្ទុកលើវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងបច្ចេកទេសល្បែង។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគ.ល.ក. ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៣ ._**

អគ្គលេខាធិការនិងអគ្គលេខាធិការរងនៃគ.ល.ក. មានលក្ខណសម្បត្តិដូចខាងក្រោម៖

ក. មានកេរ្តិ៍ឈ្មោះ ចរិតលក្ខណៈល្អ ស្មោះត្រង់ និងសុចរិត។

ខ. មានក្របខ័ណ្ឌជាមន្ត្រីមុខងារសាធារណៈដែលធ្លាប់បម្រើការងារនិងមានអតីតភាពចាប់ពី២០(ម្ភៃ) ឆ្នាំឡើងទៅ និងមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងមហាផ្ទៃ។

គ. មិនជាប់ពាក់ព័ន្ធសកម្មនឹងល្បែងពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជានិង/ឬមិនមានផលប្រយោជន៍ហិរញ្ញវត្ថុដោយផ្ទាល់ជាមួយប្រតិបត្តិករកាស៊ីណូ កម្មសិទ្ធិករនៃមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬនៃគ្រឹះស្ថានល្បែងពាណិជ្ជកម្ម ឬភាគីពាក់ព័ន្ធទេ។

## ផ្នែកទី៣

## ធនធានហិរញ្ញវត្ថុ គ.ល.ក.

**មាត្រា១៤ .-**

គ.ល.ក.មានថវិកាស្វយ័តមួយ ដើម្បីទ្រទ្រង់ការបំពេញមុខងារនិងភារកិច្ចប្រកបដោយប្រសិទ្ធភាព។ ប្រភពចំណូលរបស់គ.ល.ក. មានដូចខាងក្រោម៖

ក. កម្រៃអាជ្ញាបណ្ណនិងសោហ៊ុយទម្រង់ការលើការពិនិត្យវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណកាស៊ីណូ អាជ្ញាបណ្ណល្បែងភ្នាល់ អាជ្ញាបណ្ណល្បែងផ្សងសំណាង អាជ្ញាបណ្ណល្បែងពាណិជ្ជកម្មដទៃទៀត អាជ្ញាបណ្ណបុគ្គលិកពិសេស អាជ្ញាបណ្ណអ្នកជំរុញល្បែងពាណិជ្ជកម្ម និងអាជ្ញាបណ្ណអ្នកផលិត អ្នកដំឡើង អ្នកនាំចូល អ្នកលក់ ឬអ្នកចែកចាយឧបករណ៍ និងកម្មវិធីល្បែង ដូចមានចែងក្នុងច្បាប់នេះ។

ខ. កម្រៃលើតុល្បែង ម៉ាស៊ីនល្បែង ឧបករណ៍ និងកម្មវិធីល្បែងគ្រប់ប្រភេទ។

គ. កម្រៃពីការផាកពិន័យផ្សេងៗ។

ឃ. សោហ៊ុយទម្រង់ការឬកម្រៃសេវាផ្សេងៗរបស់គ.ល.ក.។

ង. ប្រាក់ចំណូលស្របច្បាប់ ដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

ច. ប្រាក់ចំណូលស្របច្បាប់ដទៃទៀតដែលគ.ល.ក.ត្រូវទទួលសម្រាប់បម្រើដល់គោលដៅរបស់ខ្លួន ក្រៅពីមូលនិធិសម្រាប់បម្រើការអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍។

**មាត្រា១៥ .-**

ធនធានហិរញ្ញវត្ថុរបស់គ.ល.ក. ត្រូវប្រើប្រាស់ក្នុងគោលដៅដូចខាងក្រោម៖

ក. ចំណាយសម្រាប់ទ្រទ្រង់ដល់គ.ល.ក.។

ខ. សិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងការអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ វិស័យល្បែងពាណិជ្ជកម្ម និងប្រតិបត្តិការល្បែងពាណិជ្ជកម្ម ប្រកបដោយការទទួលខុសត្រូវ។

គ. បម្រើកិច្ចការសង្គម ដើម្បីទប់ស្កាត់ជាអតិបរមានូវការប៉ះពាល់អវិជ្ជមានពីល្បែងពាណិជ្ជកម្ម។

ឃ. ចំណាយចាំបាច់ដទៃទៀត តាមការសម្រេចរបស់គ.ល.ក.។

**មាត្រា១៦ .-**

ការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋរបស់គ.ល.ក.ត្រូវកំណត់ដោយអនុក្រឹត្យ ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

**មាត្រា១៧ .-**

គ.ល.ក. គឺជាកម្មវត្ថុនៃការធ្វើសវនកម្មនិងអធិការកិច្ចស្របតាមច្បាប់ជាធរមាន។ គ.ល.ក.ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗរបស់ខ្លួន ស្របតាមស្តង់ដា បែបបទ និងនីតិវិធីគណនេយ្យជាធរមាន។

## ជំពូកទី៣

## តំបន់ល្បែងពាណិជ្ជកម្មនិងក្របខ័ណ្ឌនៃការអភិវឌ្ឍ មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍និងល្បែងពាណិជ្ជកម្ម

### ផ្នែកទី១

### តំបន់ល្បែងពាណិជ្ជកម្ម

**មាត្រា១៨ .-**

តំបន់ល្បែងពាណិជ្ជកម្មត្រូវបែងចែកជា៖

១. តំបន់ហាមឃាត់។ និង

២. តំបន់អនុញ្ញាត។

ល្បែងកាស៊ីណូនិងល្បែងភ្នាល់ត្រូវបានអនុញ្ញាតឱ្យដំណើរការតែក្នុងបរិវេណកាស៊ីណូប៉ុណ្ណោះ។

**មាត្រា១៩ .-**

តំបន់ហាមឃាត់ គឺជាទីតាំងភូមិសាស្ត្រដែលត្រូវហាមឃាត់ចំពោះល្បែងពាណិជ្ជកម្មគ្រប់ប្រភេទ ឬចំពោះល្បែងពាណិជ្ជកម្មមួយចំនួន ដោយមូលហេតុអភិរក្ស វប្បធម៌ សាសនា ឬដោយសេចក្តីត្រូវការចាំបាច់ ឬមូលហេតុផ្សេងទៀត។ ទីតាំងជាក់ស្តែងនៃតំបន់ហាមឃាត់និងប្រភេទល្បែងពាណិជ្ជកម្មដែលត្រូវរងការហាមឃាត់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២០ .-**

តំបន់អនុញ្ញាតគឺជាទីតាំងភូមិសាស្ត្រទាំងឡាយណាក្រៅពីតំបន់ហាមឃាត់។

**មាត្រា២១ .-**

គ្រឹះស្ថានល្បែងពាណិជ្ជកម្មដែលមានអាជ្ញាបណ្ណស្រាប់មុនច្បាប់នេះចូលជាធរមាននិងដែលស្ថិតនៅក្នុងតំបន់ហាមឃាត់ ត្រូវចាត់ទុកថាជាករណីអនុគ្រោះ។ គ្រឹះស្ថានល្បែងពាណិជ្ជកម្មទាំងនោះអាចប្រែក្លាយទៅជាមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ដោយបំពេញតាមលក្ខខណ្ឌចាំបាច់នានានិងត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃការអភិវឌ្ឍនិងកម្មសិទ្ធិនៃមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ដូចមានចែងក្នុងផ្នែកទី២និងទី៣នៃជំពូកនេះ។

### ផ្នែកទី២

### ក្របខ័ណ្ឌនៃការអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍

ការអភិវឌ្ឍនិងកម្មសិទ្ធិនៃមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ត្រូវអនុវត្តក្រោមកិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

កម្មសិទ្ធិករនៃមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ត្រូវបានអនុញ្ញាតឱ្យស្នើសុំអាជ្ញាបណ្ណកាស៊ីណូក្រោមបទប្បញ្ញត្តិនៃផ្នែកទី២ ជំពូកទី៤នៃច្បាប់នេះ ឬអាចទាក់ទងឱ្យប្រតិបត្តិករកាស៊ីណូមួយឬច្រើនដំណើរការល្បែងពាណិជ្ជកម្ម នៅក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍របស់ខ្លួន ស្របតាមខ្លឹមសារនិងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ដែលពាក់ព័ន្ធនិងអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ អាចបង្កើតកិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍មួយឬច្រើន ប៉ុន្តែកិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍នីមួយៗត្រូវបានអនុញ្ញាតឱ្យអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍តែមួយប៉ុណ្ណោះ។

**មាត្រា២៣ ._**

ល្បែងពាណិជ្ជកម្មអាចដំណើរការបាននៅក្នុងតំបន់ពាណិជ្ជកម្មសេរីរបស់អាកាសយានដ្ឋាន កំពង់ផែអន្តរជាតិ និងនាវាទេសចរណ៍ ដែលស្ថិតនៅក្នុងតំបន់អនុញ្ញាតដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីគ.ល.ក.ទៅតាមករណីនីមួយៗ។

ប្រតិបត្តិករកាស៊ីណូអាចដំណើរការល្បែងពាណិជ្ជកម្ម ក្រោមបទប្បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើបានលុះត្រាតែមានកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូជាមួយកម្មសិទ្ធិករឬសម្បទានិក ឬអ្នកគ្រប់គ្រងនៃអាកាសយានដ្ឋាន កំពង់ផែអន្តរជាតិ ឬនាវាទេសចរណ៍ តាមករណីជាក់ស្តែង។

## ផ្នែកទី៣
## ការអនុម័តលើការអភិវឌ្ឍនិងកម្មសិទ្ធិមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍

**មាត្រា២៤ ._**

គ.ល.ក. ត្រូវកំណត់តាមការចាំបាច់នូវទឹកប្រាក់អប្បបរមានៃគម្រោងអភិវឌ្ឍន៍ ដែលអ្នកស្នើសុំមានកាតព្វកិច្ចត្រូវអនុវត្តស្របតាមកិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ដើម្បីទទួលបានសិទ្ធិក្នុងការអភិវឌ្ឍនិងធ្វើជាកម្មសិទ្ធិករលើមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍។

ទឹកប្រាក់អប្បបរមានៃគម្រោងអភិវឌ្ឍន៍ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ដែលសម្រេចដោយគ.ល.ក.ត្រូវផ្អែកលើចំនួននៃមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ដែលបានអនុម័តរួច និងផ្អែកលើដំណាក់កាលនៃការអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ និងល្បែងពាណិជ្ជកម្មនិងកម្រិតនៃការសម្រេចបាន។

**មាត្រា២៥ ._**

មានតែនីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្មនិងចុះបញ្ជីពន្ធដារស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទេ ដែលអាចដាក់ពាក្យស្នើសុំអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ហើយនីតិបុគ្គលនោះ ត្រូវមានសិទ្ធិនៃកម្មសិទ្ធិលើទីតាំងមួយឬច្រើនរបស់ខ្លួន។

ពាក្យស្នើសុំអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ក៏អាចធ្វើបានដែរដោយនីតិបុគ្គលដែលមានសិទ្ធិកាន់កាប់ណាមួយលើទីតាំងមួយឬច្រើនកន្លែងនៅក្នុងលក្ខខណ្ឌដែលសិទ្ធិនោះអាចអនុវត្តបានតាមការសម្រេចចិត្តរបស់អ្នកដាក់ពាក្យស្នើសុំ នៅពេលដែលការអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ត្រូវបានអនុម័ត។ អ្នកដាក់ពាក្យស្នើសុំអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ត្រូវស្នើសុំនិងទទួលបានគោលការណ៍

អភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណែជាមុនពីនាយករដ្ឋមន្ត្រី មុននឹងដាក់ពាក្យស្នើសុំអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណជូនប្រធានគ.ល.ក. ដើម្បីពិនិត្យនិងសម្រេច។

ពាក្យស្នើសុំអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ ដែលត្រូវដាក់ជូនគ.ល.ក. ត្រូវភ្ជាប់មកជាមួយនូវ៖

ក. ឯកសារ និងព័ត៌មានក្នុងទម្រង់ និងតាមនីតិវិធី ដែលកំណត់ដោយគ.ល.ក.។

ខ. កម្រៃទម្រង់ការ ក្នុងចំនួន និងតាមបែបបទ ដែលកំណត់ដោយគ.ល.ក.។ និង

គ. ប្រាក់តម្កល់សម្រាប់ចំណាយរបស់គ.ល.ក. ក្នុងការសិក្សាស្រាវជ្រាវស៊ើបអង្កេតឬជួលជំនាញការដែលចាំបាច់ត្រូវធ្វើឡើងក្នុងដំណើរការវាយតម្លៃលើពាក្យស្នើសុំនោះ តាំងពីចាប់ផ្ដើមរហូតដល់ចប់ ក្នុងចំនួន និងតាមបែបបទដែលកំណត់ដោយគ.ល.ក.។

**មាត្រា២៦ .-**

បន្ទាប់ពីទទួលបានពាក្យស្នើសុំអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ គ.ល.ក.ត្រូវ៖

ក. ធ្វើការសិក្សា ស្រាវជ្រាវ និងសាកសួរ តាមការចាំបាច់។

ខ. តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្ដល់នូវព័ត៌មាន ឬឯកសារពាក់ព័ន្ធបន្ថែមតាមការចាំបាច់។

គ. តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្ដល់ឯកសារប្រគល់សិទ្ធិឬឯកសារបញ្ជាក់ការយល់ព្រមពាក់ព័ន្ធចាំបាច់ដើម្បីអាចធ្វើការស្រាវជ្រាវនិងសាកសួរ ឬដើម្បីទទួលបានព័ត៌មាននិងឯកសារពាក់ព័ន្ធ។

ឃ. តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្ដល់ភស្តុតាងចាំបាច់នានា។ និង

ង. ជួលជំនាញការឬទីប្រឹក្សាសម្រាប់វាយតម្លៃលើពាក្យស្នើសុំដែលចំណាយនេះជាបន្ទុករបស់អ្នកដាក់ពាក្យស្នើសុំ។

ប្រសិនមានការផ្លាស់ប្ដូរកើតឡើងពាក់ព័ន្ធនឹងព័ត៌មាននិងឯកសារដែលទាមទារដោយគ.ល.ក. ឬពាក់ព័ន្ធនឹងផ្នែកសំខាន់ណាមួយនៃពាក្យស្នើសុំ នៅមុនពេលដែលពាក្យស្នើសុំត្រូវបានទទួលឬបដិសេធ អ្នកដាក់ពាក្យស្នើសុំត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមទៅគ.ល.ក. អំពីការផ្លាស់ប្ដូរនោះ។ ក្នុងអំឡុងពេលដែលពាក្យស្នើសុំកំពុងដំណើរការ គ.ល.ក. អាចផ្ដល់អនុសាសន៍ដល់អ្នកដាក់ពាក្យស្នើសុំឱ្យកែប្រែខ្លឹមសារសំខាន់ៗមួយចំនួន រួមមាន គម្រោងអភិវឌ្ឍន៍ និងគម្រោងស្ថាបត្យកម្មជាដើម ហើយអ្នកដាក់ពាក្យស្នើសុំនឹងត្រូវបានផ្ដល់ឱកាសឱ្យមានយោបល់លើអនុសាសន៍នោះ។ ប្រសិនអ្នកដាក់ពាក្យស្នើសុំដកពាក្យស្នើសុំរបស់ខ្លួនវិញ គ.ល.ក. មានសិទ្ធិរក្សាទុកនូវសោហ៊ុយទម្រង់ការទាំងអស់។ ក្នុងករណីនេះ គ.ល.ក. ត្រូវផ្ទេរទៅឱ្យអ្នកដាក់ពាក្យស្នើសុំនូវចំនួនទឹកប្រាក់ដែលបានតម្កល់និងមិនទាន់ប្រើប្រាស់ អនុលោមតាមចំណុច(គ) កថាខណ្ឌទី៣នៃមាត្រា២៥ នៃច្បាប់នេះ។ សេចក្ដីបញ្ជាក់របស់គ.ល.ក. អំពីចំណាយលើការសិក្សាស្រាវជ្រាវរបស់ខ្លួន គឺជាភស្តុតាងគ្រប់គ្រាន់សម្រាប់ប្រភេទចំណាយនេះ ដែលជាបន្ទុករបស់អ្នកដាក់ពាក្យស្នើសុំ។

ពាក្យស្នើសុំព័ត៌មាននិងឯកសារពាក់ព័ន្ធទាំងអស់ដែលអ្នកដាក់ពាក្យស្នើសុំនីតិបុគ្គលឬរូបវន្តបុគ្គលពាក់ព័ន្ធណាក្ដី ផ្ដល់ជូនគ.ល.ក. ត្រូវចាត់ទុកជាព័ត៌មានសម្ងាត់ ហើយព័ត៌មាននិងឯកសារទាំងនេះមិនត្រូវបានបើកសម្ដែងចំពោះបុគ្គលណាមួយក្រៅពីអ្នកដាក់ពាក្យស្នើសុំតំណាងស្របច្បាប់ឬមេធាវីរបស់អ្នកដាក់ពាក្យស្នើសុំឡើយ លើកលែងតែអ្នកដាក់ពាក្យស្នើសុំ ឬគ.ល.ក. បានកំណត់ដោយឡែក។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា២៧.-**

ក្នុងការពិនិត្យលើពាក្យស្នើសុំ គ.ល.ក. ត្រូវពិចារណាលើលក្ខខណ្ឌវិនិច្ឆ័យ ដូចតទៅ៖

អ្នកដាក់ពាក្យស្នើសុំ៖

ក. មានធនធានហិរញ្ញវត្ថុឬមានលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់ធានានិរន្តរភាពហិរញ្ញវត្ថុនិងធានានូវដំណើរការនិងការគ្រប់គ្រងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍។ និង

ខ. មានសមត្ថភាពធុរកិច្ចនិងបទពិសោធគ្រប់គ្រាន់ឬមានលទ្ធភាពទាក់ទងប្រើប្រាស់សេវាកម្មរបស់នីតិបុគ្គលឬរូបវន្តបុគ្គលដែលមានសមត្ថភាពធុរកិច្ចនិងបទពិសោធគ្រប់គ្រាន់ ក្នុងការអភិវឌ្ឍនិងដំណើរការមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ប្រកបដោយជោគជ័យ។

មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ដែលស្នើសុំអភិវឌ្ឍនោះ ត្រូវមាន៖

ក. គុណភាព មានលក្ខណៈពិសេសនិងមានភាពទាក់ទាញ។

ខ. ទម្រង់ប្លង់ស្ថាបត្យកម្មដែលអនុលោមតាមបទប្បញ្ញត្តិ ចំពោះតំបន់ជាមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ភាពបន្សុីគ្នានឹងទិដ្ឋភាពធម្មជាតិជុំវិញ ព្រមទាំងសុខដុមនីយកម្មជាមួយសំណង់និងបរិស្ថានជុំវិញ។

គ. ភាពទាក់ទាញនិងសេវាទាំងឡាយសមស្រប ដោយប្រៀបធៀបនឹងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ដែលកំពុងមានស្រាប់ដោយផ្អែកលើនិន្នានុវាទនិងភាពប្លែកសម្បូរបែប ក៏ដូចជាប្រៀបធៀបជាមួយនឹងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍តំបន់និងអន្តរជាតិ។

ឃ. ភាពទាក់ទាញនិងសេវាក្នុងកម្រិតសមស្រប ដែលអាចបំពេញតាមតម្រូវការទីផ្សារ។

ង. ការចូលរួមចំណែកក្នុងការលើកកម្ពស់កិត្តិនាមព្រះរាជាណាចក្រកម្ពុជា ជាគោលដៅទេសចរណ៍និងការកម្សាន្តជាអន្តរជាតិ។ និង

ច. ទំហំទុនសមស្របសម្រាប់បង្កើតមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ រួមទាំងមានលទ្ធភាពបង្កើតការងារជូនប្រជាពលរដ្ឋក្នុងចំនួននិងគុណភាពសមស្របផងដែរ។

គ.ល.ក. អាចកំណត់លក្ខខណ្ឌវិនិច្ឆ័យបន្ថែមផ្សេងទៀតសម្រាប់ការពិនិត្យលើពាក្យស្នើសុំ។

**មាត្រា២៨.-**

គ.ល.ក.មានសិទ្ធិយល់ព្រមឬបដិសេធលើពាក្យស្នើសុំ។ គ.ល.ក. មានភារកិច្ចជូនដំណឹងទៅអ្នកស្នើសុំជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមឬការបដិសេធនោះ។ ពាក្យស្នើសុំអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍នឹងត្រូវយល់ព្រមដោយមានខ្លឹមសារនិងលក្ខខណ្ឌ និងសម្រាប់ទីតាំងដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ដែលត្រូវបានពិភាក្សានិងព្រមព្រៀងជាមួយអ្នកដាក់ពាក្យស្នើសុំ។

មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍នឹងទទួលបានសិទ្ធិអភិវឌ្ឍន៍បន្ទាប់ពី៖

ក. បានបង់ប្រាក់កក់ដែលកំណត់ដោយគ.ល.ក.សម្រាប់ធានាកាតព្វកិច្ចជាកម្មសិទ្ធិករនៃមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ក្នុងការអនុវត្តកិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ និងកិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ត្រូវបានចុះហត្ថលេខាដោយគ.ល.ក. តាមលិខិតប្រទានសិទ្ធិរបស់នាយករដ្ឋមន្ត្រីនិងផ្សព្វផ្សាយជាសាធារណៈ។

**មាត្រា២៩ .-**

លក្ខខណ្ឌនៃកិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ត្រូវមានខ្លឹមសារអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយដែលនៅជាធរមាន ហើយត្រូវមានចែងយ៉ាងហោចនូវចំណុចដូចខាងក្រោម៖

ក. ចំនួនទឹកប្រាក់និងដំណាក់កាលនៃការអភិវឌ្ឍ។

ខ. គម្រោងស្ថាបត្យកម្មនិងកាលវិភាគនៃការសាងសង់។

គ. ដំណាក់នៃការអភិវឌ្ឍនិង/ឬការសាងសង់ដែលត្រូវសម្រេចបាននិងកាលបរិច្ឆេទបញ្ចប់គម្រោង។

ឃ. ទំហំទីតាំងគិតជាភាគរយនៃទំហំផ្ទៃសរុបរបស់មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ដែលនឹងត្រូវប្រើជាទីតាំងកាស៊ីណូ ទីតាំងបដិសណ្ឋារកិច្ច ផ្សារទំនើប ភោជនីយដ្ឋាន មណ្ឌលកម្សាន្ត និងទស្សនាមណ្ឌលសន្និបាតឬពិព័រណ៍ ទៅតាមករណីជាក់ស្តែង។

ង. ចំនួនសណ្ឋាគារ ចំណាត់ថ្នាក់សណ្ឋាគារ និងចំនួនបន្ទប់អប្បបរមានៃសណ្ឋាគារនីមួយៗ។

ច. ចំនួនជាន់និងទំហំផ្ទៃសរុប នៃកាស៊ីណូនីមួយៗ។

ឆ. មណ្ឌលកម្សាន្តនិងមណ្ឌលទាក់ទាញផ្សេងៗរបស់មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍។

ជ. កាតព្វកិច្ចអភិវឌ្ឍន៍ផ្សេងទៀតក្រៅពីល្បែងពាណិជ្ជកម្ម។ និង

ឈ. កាតព្វកិច្ចក្នុងការថែរក្សានិងការធានារ៉ាប់រងការពារហានិភ័យសាធារណៈ។

កិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ត្រូវកំណត់អំពីករណីដែលនាំឱ្យមានការកែប្រែ ឬការបញ្ចប់កិច្ចព្រមព្រៀងដោយរាជរដ្ឋាភិបាល និងករណីដែលអនុញ្ញាតឱ្យ គ.ល.ក. ដាក់ពិន័យដោយផ្អែកលើកិច្ចព្រមព្រៀងនោះ។ កិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍អាចកំណត់ពីកាតព្វកិច្ចរបស់កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ក្នុងការអភិវឌ្ឍនៅក្នុងតំបន់អនុញ្ញាតនូវ៖

ក. មណ្ឌលកម្សាន្តនិងមណ្ឌលទាក់ទាញក្រៅពីល្បែងពាណិជ្ជកម្ម ដើម្បីចូលរួមធ្វើឱ្យមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ក្លាយជាទិសដៅទេសចរណ៍កម្សាន្តអន្តរជាតិមួយ។ និង

ខ. ហេដ្ឋារចនាសម្ព័ន្ធ ដែលចូលរួមអភិវឌ្ឍសេដ្ឋកិច្ច សង្គម ក្នុងតំបន់អនុញ្ញាត។

## ផ្នែកទី៤
## ក្របខ័ណ្ឌនៃការអភិវឌ្ឍកាស៊ីណូ

**មាត្រា៣០ .-**

មានតែនីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្មនិងចុះបញ្ជីពន្ធដារស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទេ ទើបអាចដាក់ពាក្យស្នើសុំអភិវឌ្ឍកាស៊ីណូ ហើយនីតិបុគ្គលនោះត្រូវមានសិទ្ធិនៃកម្មសិទ្ធិ ឬសិទ្ធិស្របច្បាប់ណាមួយ លើទីតាំងមួយឬច្រើនរបស់ខ្លួន។

ការអភិវឌ្ឍនិងកម្មសិទ្ធិលើកាស៊ីណូ ត្រូវអនុវត្តក្រោមកិច្ចព្រមព្រៀងអភិវឌ្ឍន៍កាស៊ីណូ ដែលនឹងត្រូវធ្វើឡើងរវាងអ្នកដាក់ពាក្យស្នើសុំនិងគ.ល.ក. អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ នីតិវិធីនិងបែបបទនៃការដាក់ពាក្យស្នើសុំអភិវឌ្ឍកាស៊ីណូនឹងកំណត់ដោយគ.ល.ក.។ អ្នកដាក់ពាក្យស្នើសុំអភិវឌ្ឍកាស៊ីណូត្រូវស្នើសុំនិងទទួលបានគោលការណ៍អភិវឌ្ឍន៍កាស៊ីណូជាមុនពីនាយករដ្ឋមន្ត្រី មុននឹងដាក់ពាក្យស្នើសុំអភិវឌ្ឍកាស៊ីណូជូនគ.ល.ក. ដើម្បីពិនិត្យនិងសម្រេច។

កាស៊ីណូនឹងបានទទួលសិទ្ធិអភិវឌ្ឍន៍បន្ទាប់ពី៖

ក. បានទទួលគោលការណ៍អភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ដូចមានចែងក្នុងមាត្រា២៥ នៃច្បាប់នេះពីនាយករដ្ឋមន្ត្រី។

ខ. បានបង់ប្រាក់កក់ដែលកំណត់ដោយគ.ល.ក. សម្រាប់ធានាកាតព្វកិច្ចជាកម្មសិទ្ធិករកាស៊ីណូ ក្នុងការអនុវត្តកិច្ចព្រមព្រៀងអភិវឌ្ឍន៍កាស៊ីណូ។ និង

គ. កិច្ចព្រមព្រៀងអភិវឌ្ឍន៍កាស៊ីណូត្រូវបានចុះហត្ថលេខាដោយ គ.ល.ក. និងផ្សព្វផ្សាយជាសាធារណៈ។

លក្ខខណ្ឌនៃកិច្ចព្រមព្រៀងអភិវឌ្ឍន៍កាស៊ីណូ ត្រូវមានខ្លឹមសារអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ឬបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយ ហើយត្រូវមានចែងយ៉ាងហោចនូវចំណុចដូចខាងក្រោម៖

ក. ចំនួនទឹកប្រាក់និងដំណាក់កាលនៃការអភិវឌ្ឍ។

ខ. គម្រោងស្ថាបត្យកម្មនិងកាលវិភាគនៃការសាងសង់។

គ. ជំហាននៃការអភិវឌ្ឍនិង/ឬការសាងសង់ដែលត្រូវសម្រេច និងកាលបរិច្ឆេទបញ្ចប់គម្រោង។

ឃ. ទំហំទីតាំងគិតជាភាគរយនៃទំហំផ្ទៃសរុបរបស់កាស៊ីណូ ដែលនឹងត្រូវប្រើជាទីតាំងល្បែង ទីតាំងបដិសណ្ឋារកិច្ច សណ្ឋាគារ និងភោជនីយដ្ឋាន។

ង. ចំណាត់ថ្នាក់សណ្ឋាគារនិងចំនួនបន្ទប់អប្បបរមានៃសណ្ឋាគារ។

ច. ចំនួនជាន់និងទំហំផ្ទៃសរុបនៃកាស៊ីណូ។

ឆ. កាតព្វកិច្ចអភិវឌ្ឍផ្សេងទៀតក្រៅពីល្បែងពាណិជ្ជកម្ម។ និង

ជ. កាតព្វកិច្ចក្នុងការថែរក្សានិងការធានារ៉ាប់រងការពារហានិភ័យសាធារណៈ។

## ផ្នែកទី៥
## កិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ

**មាត្រា៣១ ._**

កិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ ជាលិខិតតុបករណ៍ដែលគ្រប់គ្រងទំនាក់ទំនងរវាងប្រតិបត្តិករកាស៊ីណូនិងកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬរវាងប្រតិបត្តិករកាស៊ីណូនិងកម្មសិទ្ធិករកាស៊ីណូ។ កិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ មិនត្រូវមានរយៈពេលលើសពីសុពលភាពនៃអាជ្ញាបណ្ណកាស៊ីណូឡើយ។

ភាគីនៃកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ អាចកំណត់ខ្លឹមសារនិងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះដែលជាកម្មវត្ថុនៃការអនុម័តរបស់គ.ល.ក. ដោយមិនមានការប៉ះពាល់ដល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀតដូចមានចែងក្នុងមាត្រា១០និងមាត្រា១១នៃច្បាប់នេះ។

កិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ ត្រូវអនុម័តដោយគ.ល.ក.។ ក្នុងការអនុម័តនេះ គ.ល.ក.អាចកំណត់ខ្លឹមសារនិងលក្ខខណ្ឌណាដែលទាក់ទងនឹងគោលនយោបាយសាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវផ្ទុយនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ។

ខ្លឹមសារទាំងឡាយនៃមាត្រានេះ មិនត្រូវអនុវត្តចំពោះកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ និងកម្មសិទ្ធិករកាស៊ីណូ ដែលបានទទួលអាជ្ញាបណ្ណកាស៊ីណូស្របតាមខ្លឹមសារមាត្រា៣៧នៃច្បាប់នេះទេ។

**មាត្រា៣២ ._**

ត្រូវមានការយល់ព្រមជាមុនពីគ.ល.ក. ក្នុងករណីដូចខាងក្រោម៖

ក- ការកែប្រែនូវកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ។

ខ- ការបន្ថែមឧបសម្ព័ន្ធឬការមានកិច្ចព្រមព្រៀងបំពេញបន្ថែម និងការកែប្រែឧបសម្ព័ន្ធឬកិច្ចព្រមព្រៀងបំពេញបន្ថែមនោះ។

គ- មានកិច្ចព្រមព្រៀងដោយឡែករវាងកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ឬកម្មសិទ្ធិករកាស៊ីណូនិងប្រតិបត្តិករកាស៊ីណូស្តីពីទំនាក់ទំនងនៃភាគីទាំងពីរ នៅក្រោមស្មារតីនៃកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ។ ឬ

ឃ- មានកិច្ចព្រមព្រៀងដោយឡែកដែលប្រតិបត្តិករកាស៊ីណូផ្ទេរសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនទាំងស្រុងឬមួយផ្នែកនៅក្រោមស្មារតីនៃកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ។

ខ្លឹមសារនិងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ អាចត្រូវបានកែប្រែតាមការកំណត់របស់ គ.ល.ក. ដោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសំណើកែប្រែនោះទៅប្រតិបត្តិករកាស៊ីណូ និងកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ឬកម្មសិទ្ធិករកាស៊ីណូ នៅពេលមានការចាំបាច់បំផុត ដើម្បីឱ្យស្របទៅតាមការកែប្រែណាមួយនៃអាជ្ញាបណ្ណកាស៊ីណូ ដូចមានចែងនៅក្នុងមាត្រា៤៣នៃច្បាប់នេះ។

កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ឬកម្មសិទ្ធិករកាស៊ីណូ និងប្រតិបត្តិករកាស៊ីណូអាចមានយោបល់ទៅលើសំណើកែប្រែរបស់គ.ល.ក. ហើយគ.ល.ក.ត្រូវពិចារណាលើយោបល់នោះ ដើម្បីសម្រេចលើការកែប្រែ។ គ.ល.ក.ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅប្រតិបត្តិករកាស៊ីណូឬកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬកម្មសិទ្ធិករកាស៊ីណូ អំពីការសម្រេចរបស់គ.ល.ក. លើការកែប្រែដែលត្រូវមានអានុភាពតាមកាលបរិច្ឆេទដូចមានបញ្ជាក់ក្នុងសេចក្តីជូនដំណឹង។

**មាត្រា៣៣ .-**

ក្នុងករណីមានការអនុញ្ញាតនៅក្នុងកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ ប្រតិបត្តិករកាស៊ីណូអាចចុះកិច្ចសន្យាគ្រប់គ្រងកាស៊ីណូឬជាភាគីនៃកិច្ចសន្យាកែប្រែ ដើម្បីផ្ទេរកាតព្វកិច្ចទាំងស្រុងឬមួយផ្នែករបស់ខ្លួននៅក្នុងកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូទៅឱ្យអ្នកគ្រប់គ្រងកាស៊ីណូ។ ប្រតិបត្តិករកាស៊ីណូត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គ.ល.ក. យ៉ាងតិច៣០ថ្ងៃ មុនពេលចុះកិច្ចសន្យាឬមុនពេលក្លាយជាភាគីនៃកិច្ចសន្យាកែប្រែនោះ ដោយភ្ជាប់ជាមួយនូវច្បាប់ចម្លងទាំងស្រុងនៃកិច្ចសន្យាគ្រប់គ្រងកាស៊ីណូឬកិច្ចសន្យាកែប្រែនោះនិងត្រូវបញ្ជាក់នូវចំណុចសំខាន់ៗនៃកិច្ចសន្យានោះ តាមទម្រង់និងបែបបទកំណត់ដោយ គ.ល.ក. ។

មុនពេលចុះកិច្ចសន្យាឬក្លាយជាភាគីនៃកិច្ចសន្យាកែប្រែ គ.ល.ក.អាចតម្រូវឱ្យប្រតិបត្តិករកាស៊ីណូធ្វើការស៊ើបអង្កេតមួយលើគុណវុឌ្ឍិរបស់អ្នកគ្រប់គ្រងកាស៊ីណូ។ នៅក្នុងអំឡុងពេលនេះ ប្រតិបត្តិករកាស៊ីណូមិនត្រូវចុះកិច្ចសន្យាគ្រប់គ្រងកាស៊ីណូឬកិច្ចសន្យាកែប្រែដើម្បីផ្ទេរកាតព្វកិច្ចទេ រហូតទទួលបានការយល់ព្រមពី គ.ល.ក.។

អ្នកគ្រប់គ្រងកាស៊ីណូត្រូវមានគុណវុឌ្ឍិជាភាគីពាក់ព័ន្ធ ហើយក្នុងករណីនេះ បញ្ញត្តិក្នុងផ្នែកទី៣នៃជំពូកទី៥ ត្រូវយកមកអនុវត្ត។

ដោយមិនមានការប៉ះពាល់ដល់ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងកាស៊ីណូ ក្រោមបញ្ញត្តិនៃច្បាប់នេះ [illegible]ប្រើសេវាពីខាងក្រៅ ប្រតិបត្តិករកាស៊ីណូដែលចុះកិច្ចសន្យាឬជាភាគីនៃកិច្ចសន្យាគ្រប់គ្រងកា[illegible]នៅតែ[illegible]ការទទួលខុសត្រូវទាំងស្រុងជានិរន្តរ៍ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ចំពោះកម្មសិទ្ធិករ

មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬកម្មសិទ្ធិករកាស៊ីណូនៅក្រោមកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ និងកាតព្វកិច្ចតាមច្បាប់នេះ។

**មាត្រា៣៤ ._**

កិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ ត្រូវបញ្ចប់ដោយស្វ័យប្រវត្តិក្នុងករណីដែលអាជ្ញាបណ្ណកាស៊ីណូត្រូវបានប្រគល់មកវិញឬត្រូវបានដកហូត និងមានអានុភាពអនុវត្តចាប់ពីថ្ងៃដែលការប្រគល់មកវិញ ឬការដកហូតនោះចូលជាធរមាន អនុលោមតាមមាត្រា៩០នៃច្បាប់នេះ។ កិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ អាចត្រូវបានបញ្ចប់គ្រប់ពេលវេលាដោយភាគីណាមួយនៃកិច្ចព្រមព្រៀង ដោយមិនគិតពីមូលហេតុនៃការបញ្ចប់នោះ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនយ៉ាងយូរ១៨០ថ្ងៃទៅភាគីម្ខាងទៀត លើកលែងតែភាគីទាំងពីរមានការព្រមព្រៀងលើរយៈពេលលើសពីនេះ។

ក្រោយពីការទទួលឬការផ្តល់ដំណឹងអំពីការបញ្ចប់កិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ ឬនៅពេលទទួលបានសេចក្តីជូនដំណឹងពីការប្រគល់មកវិញឬការដកហូតអាជ្ញាបណ្ណកាស៊ីណូ ស្របតាមមាត្រា៩០នៃច្បាប់នេះ កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ឬកម្មសិទ្ធិករកាស៊ីណូ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅគ.ល.ក. អំពីការបញ្ចប់ ការប្រគល់មកវិញ ឬការដកហូតនោះ។ ទន្ទឹមនោះ កម្មសិទ្ធិករត្រូវជំនួសប្រតិបត្តិករកាស៊ីណូដែលបានបញ្ចប់ដោយប្រតិបត្តិករកាស៊ីណូថ្មីឬត្រូវទទួលភារៈជាប្រតិបត្តិករកាស៊ីណូដោយផ្ទាល់ ក្នុងករណីដែលកម្មសិទ្ធិករនោះមានអាជ្ញាបណ្ណកាស៊ីណូស្រាប់ឬនឹងទទួលបានអាជ្ញាបណ្ណកាស៊ីណូ។

ការស្នើសុំ ឬការកែប្រែអាជ្ញាបណ្ណកាស៊ីណូ ឬការយល់ព្រមលើកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូដែលត្រូវបានធ្វើឡើងក្នុងគោលបំណងនៃកថាខណ្ឌទី២ខាងលើ ត្រូវចាត់ទុកជាកិច្ចការអាទិភាពរបស់គ.ល.ក.។ ការសម្រេចលើពាក្យស្នើសុំនោះ ត្រូវធ្វើឡើងដោយមិនលើសពីរយៈពេលនៃការជូនដំណឹងជាមុនអំពីកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូដែលមានស្រាប់ ឬមិនហួសពីកាលបរិច្ឆេទនៃការប្រគល់មកវិញ ឬការដកហូតអាជ្ញាបណ្ណកាស៊ីណូដូចបានកំណត់ដោយគ.ល.ក. ។

ក្នុងករណីមានការជំនួសសមស្របមុនពេលផុតកំណត់នៃការជូនដំណឹងជាមុន អំពីកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូដែលមានស្រាប់ ឬមុនកាលបរិច្ឆេទនៃការប្រគល់មកវិញ ឬការដកហូតអាជ្ញាបណ្ណកាស៊ីណូ កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬកម្មសិទ្ធិករកាស៊ីណូ ប្រតិបត្តិករកាស៊ីណូចាស់និងប្រតិបត្តិករកាស៊ីណូថ្មី ត្រូវសហការគ្នាក្រោមការត្រួតពិនិត្យរបស់គ.ល.ក. ដើម្បីធានាឱ្យការផ្ទេរការគ្រប់គ្រងកាស៊ីណូប្រព្រឹត្តទៅដោយមានផលប៉ះពាល់ជាអប្បបរមាចំពោះប្រតិបត្តិការកាស៊ីណូ។

ក្នុងករណីមិនមានការជំនួសសមស្របមុនពេលផុតកំណត់នៃការជូនដំណឹងជាមុនអំពីកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូដែលមានស្រាប់ ឬមុនកាលបរិច្ឆេទនៃការប្រគល់មកវិញ ឬការដកហូតអាជ្ញាបណ្ណកាស៊ីណូ គ.ល.ក. ត្រូវតែងតាំងអ្នកគ្រប់គ្រងកាស៊ីណូ១(មួយ)រូប ក្នុងលក្ខខណ្ឌសមរម្យរហូតដល់មានការជំនួសសមស្រប ហើយការគ្រប់គ្រងកាស៊ីណូ ត្រូវបានផ្ទេរទៅឱ្យប្រតិបត្តិករកាស៊ីណូថ្មី ស្របតាមបញ្ញត្តិនៃកថាខណ្ឌទី៤ខាងលើ។

ដោយមិនមានការប៉ះពាល់ដល់សិទ្ធិទទួលសំណងសម្រាប់ការខូចខាតរបស់ភាគីណាមួយ កិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូមួយ មិនត្រូវមានសុពលភាពជាថ្មីបន្ទាប់ពីបានបញ្ចប់ឡើយ លើកលែងតែភាគីនៃកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូនោះ បានព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុន។

# ជំពូកទី៤
# របបអាជ្ញាបណ្ណ
## ផ្នែកទី១
## អាជ្ញាបណ្ណ

**មាត្រា៣៥ .-**

គ.ល.ក. អាចចេញអាជ្ញាបណ្ណតាមប្រភេទនៃល្បែងពាណិជ្ជកម្មនិងសកម្មភាពពាក់ព័ន្ធដូចខាងក្រោម៖

- អាជ្ញាបណ្ណកាស៊ីណូ
- អាជ្ញាបណ្ណល្បែងភ្នាល់
- អាជ្ញាបណ្ណល្បែងផ្សងសំណាង
- អាជ្ញាបណ្ណល្បែងពាណិជ្ជកម្មដទៃទៀត
- អាជ្ញាបណ្ណបុគ្គលិកពិសេស
- អាជ្ញាបណ្ណអ្នកជំរុញល្បែងពាណិជ្ជកម្ម និង
- អាជ្ញាបណ្ណអ្នកផលិត អ្នកដំឡើង អ្នកនាំចូល អ្នកលក់ និង/ឬអ្នកចែកចាយឧបករណ៍និង/ឬកម្មវិធីល្បែង។

នីតិបុគ្គលអាចប្រតិបត្តិការល្បែងពាណិជ្ជកម្មបាន លុះត្រាតែមានអាជ្ញាបណ្ណជាមុន អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

គ្មានបុគ្គលណាអាចតាំងខ្លួនជាតំណាងរបស់អ្នកកាន់កាប់អាជ្ញាបណ្ណនិងប្រតិបត្តិករល្បែងពាណិជ្ជកម្មបានឡើយ លើកលែងតែមានការអនុញ្ញាត អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ល្បែងពាណិជ្ជកម្មគ្រប់ប្រភេទ ដែលដាក់ឱ្យដំណើរការដោយប្រតិបត្តិករល្បែងពាណិជ្ជកម្ម ត្រូវមានការអនុញ្ញាតជាមុន។

ការផ្តល់អាជ្ញាបណ្ណនៅក្រោមច្បាប់នេះ ត្រូវធ្វើឡើងនៅក្រោមលក្ខខណ្ឌដែលអ្នកកាន់អាជ្ញាបណ្ណត្រូវមានកាតព្វកិច្ចរក្សាគុណវុឌ្ឍិរបស់ខ្លួនសមស្របជាអ្នកកាន់អាជ្ញាបណ្ណ ក្នុងអំឡុងពេលដែលអាជ្ញាបណ្ណមានសុពលភាព។

## ផ្នែកទី២
## អាជ្ញាបណ្ណកាស៊ីណូ

**មាត្រា៣៦ .-**

ដើមទុនអប្បបរមាសម្រាប់ប្រតិបត្តិការល្បែងកាស៊ីណូ ត្រូវកំណត់ដោយអនុក្រឹត្យ។ រីឯដើមទុនអប្បបរមាសម្រាប់ប្រតិបត្តិការល្បែងភ្នាល់ ល្បែងផ្សងសំណាង និងល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក.។

ករណីដូចខាងក្រោមនេះ ត្រូវមានការយល់ព្រមជាមុនពីគ.ល.ក.៖

ក. ការកែប្រែលក្ខន្តិកៈក្រុមហ៊ុនរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម។

ខ. ការផ្ទេរតាមគ្រប់ទម្រង់និងរូបភាពនូវភាគហ៊ុនមានគុណវុឌ្ឍិរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម ឬភាគហ៊ុនមានគុណវុឌ្ឍិរបស់នីតិបុគ្គល ដែលជាភាគហ៊ុនិកមានគុណវុឌ្ឍិនៃប្រតិបត្តិករល្បែងពាណិជ្ជកម្ម។

គ. ការស្នើសុំសិទ្ធិសាជីវកម្មរបស់ភាគហ៊ុនិកមានគុណវុឌ្ឍិនៃប្រតិបត្តិករល្បែងពាណិជ្ជកម្ម។ និង

ឃ. ការផ្ទេរឬការផ្តល់សិទ្ធិចាត់ចែងតាមគ្រប់ទម្រង់ឬគ្រប់រូបភាពនូវកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀតទាំងស្រុងឬមួយផ្នែក ឬប្រតិបត្តិការណាមួយនៃកាស៊ីណូ ឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត។

ការផ្ទេរភាគហ៊ុនមានគុណវុឌ្ឍិរបស់នីតិបុគ្គលដែលបានចុះបញ្ជីនៅក្នុងទីផ្សារមូលបត្រកម្ពុជា និង/ឬ ទីផ្សារមូលបត្រអន្តរជាតិនានា ដូចជាទីផ្សារមូលបត្ររបស់ហុងកុង សៀងហៃ តូក្យូ ញូយ៉ក សិង្ហបុរី និង/ឬ ទីក្រុងឡុងដ៍ ត្រូវបានលើកលែងពីការស្នើសុំការអនុញ្ញាតជាមុនពីគ.ល.ក. ដែលជាការតម្រូវក្នុងចំណុច(ខ) នៃកថាខណ្ឌទី២ខាងលើ។ បន្ទាប់ពីទទួលបានការអនុញ្ញាតណាមួយ ដែលបានកំណត់ក្នុងកថាខណ្ឌទី២ខាងលើ ឬបន្ទាប់ពីបានចុះបញ្ជីក្រុមហ៊ុន ប្រតិបត្តិករល្បែងពាណិជ្ជកម្មត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគ.ល.ក. ក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ។

**មាត្រា៣៧ .-**

មានតែកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណឬនីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដារស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបានចុះកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ ជាមួយកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណទេ ទើបអាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណកាស៊ីណូបាន។

កថាខណ្ឌទី១ខាងលើ ត្រូវយកមកអនុវត្តផងដែរ ចំពោះកម្មសិទ្ធិករកាស៊ីណូឬនីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្មនិងចុះបញ្ជីពន្ធដារស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបានចុះកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូជាមួយកម្មសិទ្ធិករកាស៊ីណូ។

ពាក្យស្នើសុំអាជ្ញាបណ្ណកាស៊ីណូត្រូវដាក់ជូនគ.ល.ក. ដោយភ្ជាប់មកជាមួយនូវ៖

ក. ឯកសារនិងព័ត៌មានក្នុងទម្រង់និងតាមនីតិវិធីដែលកំណត់ដោយគ.ល.ក.។

ខ- កម្រៃទម្រង់ការក្នុងចំនួននិងតាមបែបបទដែលកំណត់ដោយគ.ល.ក.។

គ. ប្រាក់តម្កល់សម្រាប់ចំណាយរបស់គ.ល.ក.ក្នុងការសិក្សា ស្រាវជ្រាវ ស៊ើបអង្កេត ឬជួលជំនាញការជាដើម ដែលចាំបាច់ត្រូវធ្វើឡើងក្នុងដំណើរការវាយតម្លៃលើពាក្យស្នើសុំនោះ តាំងពីចាប់ផ្តើមរហូតដល់ចប់ ក្នុងចំនួននិងតាមបែបបទដែលកំណត់ដោយគ.ល.ក.។ និង

ឃ. ប្រាក់តម្កល់សម្រាប់ធានាអាជីវកម្មតាមការកំណត់របស់គ.ល.ក.។

**មាត្រា៣៨ .-**

បន្ទាប់ពីទទួលបានពាក្យស្នើសុំអាជ្ញាបណ្ណកាស៊ីណូ គ.ល.ក. ត្រូវ៖

ក. ធ្វើការសិក្សា ស្រាវជ្រាវ និងសាកសួរ តាមការចាំបាច់។

ខ. តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មានឬឯកសារពាក់ព័ន្ធបន្ថែមតាមការចាំបាច់។

គ. តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់ឯកសារប្រគល់សិទ្ធិឬឯកសារបញ្ជាក់ការយល់ព្រមពាក់ព័ន្ធចាំបាច់ ដើម្បីឱ្យគ.ល.ក.អាចធ្វើការស្រាវជ្រាវនិងសាកសួរ ឬដើម្បីទទួលបានព័ត៌មាននិងឯកសារពាក់ព័ន្ធ។

ឃ. តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំ ផ្តល់កស្តុតាងចាំបាច់នានា។ និង

ង. ជួលជំនាញការឬទីប្រឹក្សាសម្រាប់វាយតម្លៃលើពាក្យស្នើសុំ ដែលចំណាយនេះជាបន្ទុករបស់អ្នកដាក់ពាក្យស្នើសុំ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ប្រសិនមានការផ្លាស់ប្តូរកើតឡើងពាក់ព័ន្ធនឹងព័ត៌មាននិងឯកសារដែលទាមទារដោយគ.ល.ក. ឬពាក់ព័ន្ធនឹងផ្នែកសំខាន់ណាមួយនៃពាក្យស្នើសុំ នៅមុនពេលដែលពាក្យស្នើសុំត្រូវបានទទួលឬបដិសេធ អ្នកដាក់ពាក្យស្នើសុំត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមទៅគ.ល.ក. អំពីការផ្លាស់ប្តូរនោះ។

ក្នុងអំឡុងពេលដែលពាក្យស្នើសុំកំពុងដំណើរការ គ.ល.ក. អាចផ្តល់អនុសាសន៍ដល់អ្នកដាក់ពាក្យស្នើសុំឱ្យកែប្រែខ្លឹមសារសំខាន់ៗមួយចំនួនចំពោះពាក្យស្នើសុំរបស់ខ្លួន ហើយអ្នកដាក់ពាក្យស្នើសុំនឹងត្រូវបានផ្តល់ឱកាសឱ្យមានយោបល់លើអនុសាសន៍នោះ។

ប្រសិនអ្នកដាក់ពាក្យស្នើសុំដកពាក្យស្នើសុំរបស់ខ្លួនវិញ គ.ល.ក.មានសិទ្ធិរក្សាទុកនូវសោហ៊ុយទម្រង់ការទាំងអស់។ ក្នុងករណីនេះ គ.ល.ក.ត្រូវផ្ទេរទៅឱ្យអ្នកដាក់ពាក្យស្នើសុំនូវចំនួនទឹកប្រាក់ដែលបានតម្កល់និងមិនទាន់ប្រើប្រាស់ អនុលោមតាមច្បាប់នេះ។

សេចក្តីបញ្ជាក់របស់គ.ល.ក.អំពីចំណាយលើការសិក្សាស្រាវជ្រាវរបស់ខ្លួន គឺជាភស្តុតាងគ្រប់គ្រាន់សម្រាប់ប្រភេទចំណាយនេះ ដែលជាបន្ទុករបស់អ្នកដាក់ពាក្យស្នើសុំ។

ពាក្យស្នើសុំព័ត៌មាននិងឯកសារពាក់ព័ន្ធទាំងអស់ដែលផ្តល់ជូនគ.ល.ក. ត្រូវចាត់ទុកជាព័ត៌មានសម្ងាត់ ហើយព័ត៌មាននិងឯកសារទាំងនេះមិនត្រូវបានបើកចំហចំពោះបុគ្គលណាមួយក្រៅពីអ្នកដាក់ពាក្យស្នើសុំតំណាងស្របច្បាប់ឬមេធាវីរបស់អ្នកដាក់ពាក្យស្នើសុំឡើយ លើកលែងតែអ្នកដាក់ពាក្យស្នើសុំឬគ.ល.ក. បានកំណត់ដោយឡែក។

**មាត្រា៣៩ ._**

គ.ល.ក.ត្រូវពិចារណានិងសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ដោយយោងតាមលក្ខខណ្ឌវិនិច្ឆ័យដូចតទៅ៖

១. អ្នកដាក់ពាក្យស្នើសុំត្រូវមាន៖

ក. រចនាសម្ព័ន្ធអាជីវកម្មសមស្របនិងមានលក្ខន្តិកៈក្រុមហ៊ុន។

ខ. ធនធានហិរញ្ញវត្ថុឬមានលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ធានានិរន្តរភាពហិរញ្ញវត្ថុនិងធានានូវដំណើរការ និងការគ្រប់គ្រងកាស៊ីណូ។ និង

គ. សមត្ថភាពធុរកិច្ចនិងបទពិសោធន៍ល្បែងពាណិជ្ជកម្មគ្រប់គ្រាន់ឬបានទាក់ទងប្រើប្រាស់សេវាកម្មរបស់នីតិបុគ្គលឬរូបវន្តបុគ្គលដែលមានសមត្ថភាពធុរកិច្ចនិងបទពិសោធល្បែងពាណិជ្ជកម្មគ្រប់គ្រាន់ក្នុងការបង្កើតនិងដំណើរការកាស៊ីណូប្រកបដោយជោគជ័យ។

២. ភាគហ៊ុនិកដែលមានគុណវុឌ្ឍិឬបុគ្គលិកពិសេសរបស់អ្នកដាក់ពាក្យស្នើសុំ៖

ក. ជាបុគ្គលដែលមានកេរ្តិ៍ឈ្មោះល្អ ចរិតលក្ខណៈល្អ ស្មោះត្រង់និងសុចរិត។ និង

ខ. ជាបុគ្គលដែលមានមូលដ្ឋានហិរញ្ញវត្ថុល្អនិងមានស្ថិរភាពសមរម្យ។

៣. កិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូរវាងប្រតិបត្តិករកាស៊ីណូនិងកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ឬកម្មសិទ្ធិករកាស៊ីណូដែល៖

ក. អនុញ្ញាតឱ្យគ.ល.ក.អនុវត្តការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើប្រតិបត្តិការកាស៊ីណូ និងលើប្រតិបត្តិករកាស៊ីណូ។

ខ. [illegible]មានការប៉ះពាល់អវិជ្ជមានចំពោះទីផ្សារល្បែងពាណិជ្ជកម្ម ដោយបង្កឱ្យមានការប្រកួតប្រជែងមិនសមស្រប ចំពោះប្រតិបត្តិករកាស៊ីណូដែលមានស្រាប់និងប្រតិបត្តិករនាអនាគត។ និង

គ. [illegible]បទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ។

**មាត្រា៤០.-**

គ.ល.ក.មានសិទ្ធិយល់ព្រមឬបដិសេធលើពាក្យស្នើសុំ។ គ.ល.ក.មានភារកិច្ចជូនដំណឹងទៅអ្នកស្នើសុំជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចរបស់ខ្លួន។

អាជ្ញាបណ្ណកាស៊ីណូនឹងត្រូវសម្រេចយល់ព្រមអនុលោមតាមខ្លឹមសារនិងលក្ខខណ្ឌដែលកំណត់ដោយ គ.ល.ក. ដោយមិនផ្ទុយពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ។

អាជ្ញាបណ្ណកាស៊ីណូត្រូវកំណត់អំពីប្រភេទល្បែងពាណិជ្ជកម្ម និងចំនួនអតិបរមានៃតុល្បែង ម៉ាស៊ីនល្បែង ឧបករណ៍ និងកម្មវិធីល្បែងនៃល្បែងពាណិជ្ជកម្ម ដែលប្រតិបត្តិករកាស៊ីណូដាក់ឱ្យដំណើរការក្នុងកាស៊ីណូនោះ។

អាជ្ញាបណ្ណកាស៊ីណូនឹងមានប្រសិទ្ធភាពបន្ទាប់ពី៖

ក. បានបង់កម្រៃអាជ្ញាបណ្ណនិងប្រាក់តម្កល់ក្នុងចំនួននិងតាមបែបបទ ដែលកំណត់ដោយគ.ល.ក. ក្នុងគោលបំណងធានានូវកាតព្វកិច្ចគតិយុត្តនិងកាតព្វកិច្ចអាជ្ញាបណ្ណរបស់ប្រតិបត្តិករកាស៊ីណូ។

ខ. មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ឬកាស៊ីណូ ដែលមានបញ្ជាក់ក្នុងអាជ្ញាបណ្ណបានទទួលការអនុញ្ញាតឱ្យបើកកាស៊ីណូ។ និង

គ. អាជ្ញាបណ្ណកាស៊ីណូនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ។

**មាត្រា៤១.-**

អាជ្ញាបណ្ណកាស៊ីណូត្រូវបានផ្តល់ឱ្យសម្រាប់រយៈពេលកំណត់ក្នុងអាជ្ញាបណ្ណ ដែលមិនលើសពី២០ (ម្ភៃ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយអាជ្ញាបណ្ណកាស៊ីណូជាសាធារណៈ។

សុពលភាពនៃអាជ្ញាបណ្ណកាស៊ីណូដូចបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើ អនុវត្តចំពោះតែអាជ្ញាបណ្ណកាស៊ីណូស្ថិតក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ប៉ុណ្ណោះ។ ចំពោះកាស៊ីណូដែលមិនស្ថិតនៅក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ អាជ្ញាបណ្ណត្រូវបានផ្តល់ឱ្យសម្រាប់រយៈពេល មិនលើសពី៥(ប្រាំ)ឆ្នាំ។

ប្រតិបត្តិករកាស៊ីណូអាចដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណកាស៊ីណូទៅគ.ល.ក.ក្នុងរយៈពេលយ៉ាងតិច៦(ប្រាំមួយ)ខែ មុនពេលផុតសុពលភាពអាជ្ញាបណ្ណនោះដែលក្នុងករណីនេះ បញ្ញត្តិនៃមាត្រា៣៧ ដល់មាត្រា៤៥នៃច្បាប់នេះ ត្រូវយកមកអនុវត្តដោយមានការកែប្រែតាមការចាំបាច់។

ក្នុងករណីដែលប្រតិបត្តិករកាស៊ីណូមិនដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណកាស៊ីណូ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងកថាខណ្ឌទី៣ខាងលើ ឬពាក្យស្នើសុំបន្តសុពលភាពត្រូវបានបដិសេធ បញ្ញត្តិនៃកថាខណ្ឌទី៣ដល់ទី៦នៃមាត្រា៣៤នៃច្បាប់នេះត្រូវយកមកអនុវត្ត។

**មាត្រា៤២.-**

អាជ្ញាបណ្ណកាស៊ីណូដែលមិនមានដំណើរការល្បែងពាណិជ្ជកម្ម មិនអាចត្រូវយកទៅដាក់បញ្ចាំ ដាក់ហ៊ីប៉ូតែក និង/ឬត្រូវបានផ្ទេរឡើយ។

អាជ្ញាបណ្ណកាស៊ីណូដែលមានដំណើរការល្បែងពាណិជ្ជកម្មអាចត្រូវបានយកទៅដាក់បញ្ចាំ ដាក់ហ៊ីប៉ូតែក និង/ឬត្រូវបានផ្ទេរសម្រាប់គោលបំណងពាណិជ្ជកម្ម។ រាល់ការផ្ទេរអាជ្ញាបណ្ណកាស៊ីណូដែលមានដំណើរការល្បែងពាណិជ្ជកម្ម អាចត្រូវធ្វើឡើងបានតែក្នុងករណីដែលការផ្ទេរនោះធ្វើឡើងទៅកាន់នីតិបុគ្គល ដែលគ្រប់គ្រងដោយមានភាពសុចរិតនិងមានលក្ខណសម្បត្តិល្អ និងដែលមិនមានជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម។

រាល់ការផ្ទេរអាជ្ញាបណ្ណកាស៊ីណូដែលមានដំណើរការល្បែងពាណិជ្ជកម្ម ត្រូវមានការយល់ព្រមជាមុនពី

**មាត្រា៤៣ ._**

ខ្លឹមសារនិងលក្ខខណ្ឌអាជ្ញាបណ្ណកាស៊ីណូ អាចកែប្រែបាននៅក្នុងករណីដូចខាងក្រោម៖

ក. មានការស្នើសុំជាលាយលក្ខណ៍អក្សរពីប្រតិបត្តិករកាស៊ីណូទៅគ.ល.ក.។ ឬ

ខ. តាមការសម្រេចរបស់គ.ល.ក.ក្នុងបរិបទនៃការដាក់ទណ្ឌកម្មរដ្ឋបាល ចំពោះប្រតិបត្តិករកាស៊ីណូដែលបំពានលើខ្លឹមសារនិងលក្ខខណ្ឌនៃអាជ្ញាបណ្ណកាស៊ីណូ។

ប្រតិបត្តិករកាស៊ីណូត្រូវទទួលបានឱកាសក្នុងការបញ្ចេញមតិយោបល់ចំពោះការស្នើសុំកែប្រែឬការកែប្រែដែលកំណត់ដោយគ.ល.ក. តាមករណីជាក់ស្តែង។ ការកែប្រែដែលកំណត់ដោយគ.ល.ក. ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅប្រតិបត្តិករកាស៊ីណូនិងត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីជូនដំណឹង។

**មាត្រា៤៤ ._**

កិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍និងកិច្ចព្រមព្រៀងអភិវឌ្ឍន៍កាស៊ីណូ ត្រូវកំណត់នូវជំហានសំខាន់ៗ ដែលកាស៊ីណូនីមួយៗស្នើសុំធ្វើប្រតិបត្តិការនិងបើកដំណើរការជាសាធារណៈ ដូចមានចែងក្នុងចំណុច(គ) កថាខណ្ឌទី១នៃមាត្រា២៩ និងចំណុច(គ) កថាខណ្ឌទី៤នៃមាត្រា៣០នៃច្បាប់នេះ។

កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍និងកម្មសិទ្ធិករកាស៊ីណូត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគ.ល.ក. អំពីសមិទ្ធផលដែលសម្រេចបានតាមជំហាននីមួយៗ ដូចមានចែងក្នុងចំណុច(គ) កថាខណ្ឌទី១នៃមាត្រា២៩ និងចំណុច(គ) កថាខណ្ឌទី៤នៃមាត្រា៣០នៃច្បាប់នេះ ហើយក៏ត្រូវបញ្ជាក់ផងដែរអំពីការត្រៀមលក្ខណៈសព្វគ្រប់សម្រាប់ការបើកដំណើរការជាសាធារណៈនូវប្រតិបត្តិការកាស៊ីណូនិងស្នើសុំការអនុញ្ញាតពីគ.ល.ក. នូវការបើកដំណើរការនោះ។

ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលការជូនដំណឹង គ.ល.ក.ត្រូវចាត់ចែងការចុះធ្វើការត្រួតពិនិត្យដល់ទីកន្លែង។ ក្នុងរយៈពេល១៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបញ្ចប់ការត្រួតពិនិត្យ គ.ល.ក. ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ឬកម្មសិទ្ធិករកាស៊ីណូអំពីលទ្ធផលនៃការត្រួតពិនិត្យដោយ៖

ក. អនុញ្ញាតឱ្យបើកដំណើរការកាស៊ីណូនិងកំណត់នូវកាលបរិច្ឆេទ នៃការបើកដំណើរការនោះ។ ឬ

ខ. បដិសេធដោយបញ្ជាក់ពីមូលហេតុនិងបញ្ហាដែលកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ឬកម្មសិទ្ធិករកាស៊ីណូត្រូវដោះស្រាយមុននឹងទទួលបានការអនុញ្ញាតឱ្យបើកដំណើរការកាស៊ីណូ។

ក្នុងករណីការបើកដំណើរការកាស៊ីណូត្រូវបានបដិសេធតាមចំណុច(ខ)នៃកថាខណ្ឌទី៣ខាងលើ កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ឬកម្មសិទ្ធិករកាស៊ីណូ ត្រូវដោះស្រាយបញ្ហាដែលបានកំណត់នៅក្នុងសេចក្តីជូនដំណឹងរបស់គ.ល.ក.។ បន្ទាប់ពីបានដោះស្រាយបញ្ហាទាំងនោះ កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ឬកម្មសិទ្ធិករកាស៊ីណូត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគ.ល.ក. ដើម្បីស្នើសុំការចុះត្រួតពិនិត្យលើកទីពីរ។ កថាខណ្ឌទី២និងកថាខណ្ឌទី៣នៃមាត្រានេះ ត្រូវយកមកអនុវត្តចំពោះការចុះត្រួតពិនិត្យលើកទីពីរ។

ក្នុងករណីការបើកដំណើរការកាស៊ីណូត្រូវបានអនុញ្ញាតតាមចំណុច(ក)នៃកថាខណ្ឌទី៣នៃមាត្រានេះ កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ឬកម្មសិទ្ធិករកាស៊ីណូអាចបើកដំណើរការកាស៊ីណូនិងប្រតិបត្តិការដំណើរការអាជីវកម្មនៅក្នុងកាស៊ីណូ តាមកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីជូនដំណឹងរបស់គ.ល.ក.។

**មាត្រា៤៥ ៈ**

ប្រតិបត្តិករកាស៊ីណូដែលមានអាជ្ញាបណ្ណ ត្រូវបើកដំណើរការជាប់ជាប្រចាំសម្រាប់សាធារណជន២៤ម៉ោង ក្នុងមួយថ្ងៃ រៀងរាល់ថ្ងៃពេញមួយឆ្នាំ។ ប៉ុន្តែប្រតិបត្តិការកាស៊ីណូអាចផ្អាកឬត្រូវបិទដំណើរការជាបណ្តោះអាសន្ន ក្នុងស្ថានភាពដូចខាងក្រោម៖

ក. ក្នុងករណីការផ្អាកឬបិទដំណើរការមានរយៈពេលមិនលើសពី៧ថ្ងៃនិងដោយមានការយល់ព្រមជាមុនពីគ.ល.ក.។ ឬ

ខ. ក្នុងករណីប្រធានសក្តិ ដោយមានរយៈពេលមិនលើសពីព្រឹត្តិការណ៍នៃករណីប្រធានសក្តិនោះ។

ប្រតិបត្តិករកាស៊ីណូត្រូវផ្អាកឬបិទដំណើរការជាបណ្តោះអាសន្ន ដោយមូលហេតុសាសនា វប្បធម៌ យោងលើលក្ខខណ្ឌកំណត់ដោយគ.ល.ក. ឬតាមការចាំបាច់។

ប្រតិបត្តិករកាស៊ីណូក៏ត្រូវផ្អាកឬបិទដំណើរការកាស៊ីណូជាបណ្តោះអាសន្នផងដែរ នៅពេលមានការសម្រេចរបស់គ.ល.ក. ទោះបីជាប្រតិបត្តិករកាស៊ីណូប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់គ.ល.ក. ដែលទាក់ទងនឹងការព្យួរអាជ្ញាបណ្ណឬដកហូតអាជ្ញាបណ្ណក៏ដោយ។

## ផ្នែកទី៣

## អាជ្ញាបណ្ណបុគ្គលិកពិសេស

**មាត្រា៤៦ ៈ**

រូបវន្តបុគ្គលមិនត្រូវអនុវត្តឬបំពេញមុខងារណាមួយនៃមុខងារបុគ្គលិកពិសេសឡើយ លើកលែងតែមានអាជ្ញាបណ្ណបុគ្គលិកពិសេស អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ អ្នកកាន់កាប់អាជ្ញាបណ្ណបុគ្គលិកពិសេសម្នាក់ៗត្រូវអនុវត្តតែមុខងារដែលបានបញ្ជាក់នៅក្នុងអាជ្ញាបណ្ណបុគ្គលិកពិសេសរបស់ខ្លួនផ្ទាល់ប៉ុណ្ណោះ អនុលោមតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណបុគ្គលិកពិសេស។ ប្រតិបត្តិករល្បែងពាណិជ្ជកម្មត្រូវទទួលខុសត្រូវក្នុងការប្រើប្រាស់សេវារបស់និយោជិតខ្លួនអនុលោមតាមបទប្បញ្ញត្តិនេះ។

ចំពោះកាស៊ីណូ បុគ្គលិកពិសេសគឺជាបុគ្គលដែលបម្រើការក្នុងកាស៊ីណូនិងមានសមត្ថកិច្ចជាអ្នកគ្រប់គ្រងដែលមានសិទ្ធិធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងការចាត់ចែងលើប្រតិបត្តិការកាស៊ីណូឬបុគ្គលិកដែលមានមុខងារនិងភារកិច្ចដូចខាងក្រោម៖

ក. ដំណើរការល្បែងក្នុងកាស៊ីណូ។

ខ. ការចរាចរសាច់ប្រាក់ឬកាក់ល្បែងនៅក្នុងបរិវេណកាស៊ីណូ។

គ. ការប្តូរប្រាក់ឬកាក់ល្បែងទៅឱ្យភ្ញៀវល្បែងនៅក្នុងកាស៊ីណូ។

ឃ. ការរាប់ប្រាក់ឬកាក់ល្បែងនៅក្នុងបរិវេណកាស៊ីណូ។

ង. ការរក្សាសុវត្ថិភាពនិងការតាមដានត្រួតពិនិត្យនៅក្នុងកាស៊ីណូ។

ច. ដំណើរការ ការថែរក្សា ការដំឡើង ឬជួសជុសតុល្បែង ម៉ាស៊ីនល្បែង ឬឧបករណ៍ល្បែងពាណិជ្ជកម្មដទៃទៀតនៅក្នុងកាស៊ីណូ។

ឆ. ការគ្រប់គ្រងនិងត្រួតពិនិត្យសកម្មភាពទាំងអស់ខាងលើ។

ឆ. សកម្មភាពផ្សេងទៀតពាក់ព័ន្ធនឹងប្រតិបត្តិការកាស៊ីណូ ដែលកំណត់ដោយគ.ល.ក. ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ប្រតិបត្តិករកាស៊ីណូ។

ចំពោះគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀតក្រៅពីកាស៊ីណូ បុគ្គលិកពិសេសនឹងត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក.។

**មាត្រា៤៧ ._**

កម្មករនិយោជិតនៃគ្រឹះស្ថានល្បែងពាណិជ្ជកម្មដែលស្ថិតក្នុងចំណាត់ថ្នាក់ជាបុគ្គលិកពិសេស ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណបុគ្គលិកពិសេសពីគ.ល.ក.។

ពាក្យស្នើសុំអាជ្ញាបណ្ណបុគ្គលិកពិសេសត្រូវដាក់ជូនគ.ល.ក. ដោយភ្ជាប់មកជាមួយនូវ៖

ក. ឯកសារនិងព័ត៌មានក្នុងទម្រង់និងតាមនីតិវិធី ដែលកំណត់ដោយគ.ល.ក.។ និង

ខ. កម្រៃអាជ្ញាបណ្ណនិងសោហ៊ុយទម្រង់ការ ក្នុងចំនួននិងតាមបែបបទដែលកំណត់ដោយគ.ល.ក.។

នីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្ដល់ ការផ្ទេរ ឬ/និងការបន្តសុពលភាពអាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក.។

## ផ្នែកទី៤
## អាជ្ញាបណ្ណអ្នកជំរុញល្បែងពាណិជ្ជកម្ម

**មាត្រា៤៨ ._**

មានតែនីតិបុគ្គលដែលមានអាជ្ញាបណ្ណជំរុញល្បែងពាណិជ្ជកម្ម ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះប៉ុណ្ណោះ ទើបអាចធ្វើសកម្មភាពជំរុញល្បែងពាណិជ្ជកម្មបាន។

អ្នកជំរុញល្បែងពាណិជ្ជកម្មត្រូវបានអនុញ្ញាតឱ្យនាំភ្ញៀវល្បែងមកលេងនៅកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត ដោយដើរតួជាភ្នាក់ងាររបស់ប្រតិបត្តិករកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មមួយ ឬច្រើន ហើយសម្របសម្រួលអប្បហារ ការដឹកជញ្ជូន ការស្នាក់នៅ ការកម្សាន្ត និងអត្ថប្រយោជន៍ផ្សេងទៀតចំពោះភ្ញៀវល្បែង ជាថ្នូរនឹងកម្រៃជើងសាឬតម្លៃតបស្នងផ្សេងទៀត។ អ្នកជំរុញល្បែងពាណិជ្ជកម្ម ក៏ត្រូវបានអនុញ្ញាតផងដែរឱ្យផ្ដល់ឥណទានសម្រាប់ការលេងល្បែង ក្នុងនាមខ្លួនផ្ទាល់ឬក្នុងនាមជាភ្នាក់ងាររបស់ប្រតិបត្តិករកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្ម។

អ្នកជំរុញល្បែងពាណិជ្ជកម្ម អាចនាំនិងផ្ដល់ឥណទានដល់ភ្ញៀវល្បែងដែលមិនមែនជានិវាសនជនឬមិនមានសញ្ជាតិខ្មែរតែប៉ុណ្ណោះ។

**មាត្រា៤៩ ._**

មុនពេលចាប់ផ្ដើមប្រតិបត្តិការ អ្នកជំរុញល្បែងពាណិជ្ជកម្មត្រូវមានអាជ្ញាបណ្ណពីគ.ល.ក.។

មានតែនីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្មនិងចុះបញ្ជីពន្ធដារស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទេ ដែលអាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណជាអ្នកជំរុញល្បែងពាណិជ្ជកម្ម។ ពាក្យស្នើសុំអាជ្ញាបណ្ណនេះ ត្រូវដាក់ជូនគ.ល.ក. ដោយភ្ជាប់មកជាមួយនូវ៖

ក. ឯកសារនិងព័ត៌មានក្នុងទម្រង់និងតាមនីតិវិធី ដែលកំណត់ដោយគ.ល.ក.។ និង

ខ. កម្រៃអាជ្ញាបណ្ណនិងសោហ៊ុយទម្រង់ការ ក្នុងចំនួន និងតាមបែបបទ ដែលកំណត់ដោយគ.ល.ក.។

នីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់ ការផ្ទេរ ឬ/និងការបន្តសុពលភាពអាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក.។

**មាត្រា៥០ .-**

អ្នកជំរុញល្បែងពាណិជ្ជកម្មត្រូវមានលក្ខណៈសម្បត្តិជាភាគីពាក់ព័ន្ធនិងបន្ទាប់ពីទទួលបានអាជ្ញាបណ្ណស្របតាមមាត្រា៤៩នៃច្បាប់នេះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យនិងគ្រប់គ្រងរបស់គ.ល.ក.។ កិច្ចសន្យារវាងអ្នកជំរុញល្បែងពាណិជ្ជកម្មនិងប្រតិបត្តិករកាស៊ីណូត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានលក្ខណសម្បត្តិជាកិច្ចសន្យាត្រួតពិនិត្យ ដូចមានចែងក្នុងផ្នែកទី៣នៃជំពូកទី៥នៃច្បាប់នេះ។

អ្នកជំរុញល្បែងពាណិជ្ជកម្មក៏ត្រូវស្ថិតក្រោមកាតព្វកិច្ចត្រួតពិនិត្យផ្ទៃក្នុង ដូចមានចែងក្នុងមាត្រា៥៤នៃច្បាប់នេះ។

## ផ្នែកទី៥
## អាជ្ញាបណ្ណល្បែងភ្នាល់ អាជ្ញាបណ្ណល្បែងផ្សងសំណាង និងអាជ្ញាបណ្ណល្បែងពាណិជ្ជកម្មដទៃទៀត

**មាត្រា៥១ .-**

ប្រភេទនិងចំនួននៃអាជ្ញាបណ្ណល្បែងភ្នាល់ អាជ្ញាបណ្ណល្បែងផ្សងសំណាង និងអាជ្ញាបណ្ណល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក.។

នីតិវិធី បែបបទ កាតព្វកិច្ចផ្សេងៗ និងលក្ខខណ្ឌនៃការផ្តល់ ការផ្ទេរ និងការបន្តសុពលភាពអាជ្ញាបណ្ណដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក. ហើយលក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណ ក៏ត្រូវមានចែងផងដែរអំពីប្រាក់តម្កល់សម្រាប់ធានាអាជីវកម្មដែលប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង និងប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវរក្សាក្នុងចំនួននិងតាមបែបបទដែលកំណត់ដោយគ.ល.ក.។

ដំណើរការ ការគ្រប់គ្រង និងការត្រួតពិនិត្យល្បែងភ្នាល់ ល្បែងផ្សងសំណាង និងល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក.។

## ផ្នែកទី៦
## អាជ្ញាបណ្ណអ្នកផលិត អ្នកដំឡើង អ្នកនាំចូល អ្នកលក់ ឬអ្នកចែកចាយឧបករណ៍ និង/ឬកម្មវិធីល្បែង

**មាត្រា៥២ .-**

អាជ្ញាបណ្ណអ្នកផលិត អ្នកដំឡើង អ្នកនាំចូល អ្នកលក់ និងអ្នកចែកចាយឧបករណ៍ និង/ឬកម្មវិធីល្បែង ត្រូវកំណត់ដោយគ.ល.ក.។

នីតិវិធី បែបបទ កាតព្វកិច្ចផ្សេងៗ និងលក្ខខណ្ឌនៃការផ្តល់ ការផ្ទេរ និងការបន្តសុពលភាពអាជ្ញាបណ្ណដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក. ហើយលក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណក៏ត្រូវមានចែងផងដែរអំពីប្រាក់តម្កល់សម្រាប់ធានាអាជីវកម្ម ដែលប្រតិបត្តិករត្រូវរក្សាក្នុងចំនួននិងតាមបែបបទដែលកំណត់ដោយគ.ល.ក.។

ការគ្រប់គ្រងនិងការត្រួតពិនិត្យលើការផលិត ការដំឡើង ការនាំចូល ការលក់ឬចែកចាយឧបករណ៍ ឬកម្មវិធីល្បែងត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក.។

# ជំពូកទី៥
# ការត្រួតពិនិត្យនិងការគ្រប់គ្រងប្រតិបត្តិករល្បែងពាណិជ្ជកម្មនិងភាគីពាក់ព័ន្ធ
## ផ្នែកទី១
## ប្រតិបត្តិករល្បែងពាណិជ្ជកម្ម

**មាត្រា៥៣ ._**

ប្រតិបត្តិករល្បែងពាណិជ្ជកម្មមួយមានសិទ្ធិទិញយកភាគហ៊ុននៃប្រតិបត្តិករល្បែងពាណិជ្ជកម្ម រួមបញ្ចូលទាំងការទិញយកភាគហ៊ុនមានគុណវុឌ្ឍិនៃប្រតិបត្តិករល្បែងពាណិជ្ជកម្មផ្សេងទៀត ទោះស្ថិតនៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជាក្តី។

បុគ្គលិកពិសេសរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មមួយ មិនអាចជាភាគហ៊ុនិកមានគុណវុឌ្ឍិឬជាបុគ្គលិកពិសេសរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មផ្សេងទៀត ឬរបស់កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬកម្មសិទ្ធិករកាស៊ីណូ ឬរបស់អ្នកគ្រប់គ្រងកាស៊ីណូ ឬរបស់ភាគីពាក់ព័ន្ធណាមួយដោយផ្ទាល់ឬដោយប្រយោលឡើយ។

**មាត្រា៥៤ ._**

ប្រតិបត្តិករល្បែងពាណិជ្ជកម្ម ត្រូវមានកាតព្វកិច្ចត្រួតពិនិត្យផ្ទៃក្នុងលើចំណុចដូចខាងក្រោម៖

ក. ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ខ. ការប្រឆាំងអំពើស៊ីសំណូកនិងអំពើពុករលួយ។

គ. ការរក្សាសុវត្ថិភាពចំពោះចំណូលពីល្បែងនិងការត្រួតពិនិត្យការចូលទៅក្នុងកន្លែងហាមឃាត់។

ឃ. ការរក្សាបញ្ជីគណនេយ្យនិងកំណត់ត្រា។ និង

ង. កាតព្វកិច្ចផ្តល់របាយការណ៍សវនកម្មផ្ទៃក្នុងនិងកាតព្វកិច្ចអនុលោមភាព។

ការត្រួតពិនិត្យផ្ទៃក្នុងរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម ត្រូវស្របតាមក្របខ័ណ្ឌច្បាប់ជាធរមាន និងស្តង់ដាអប្បបរមានៃការត្រួតពិនិត្យផ្ទៃក្នុងដែលកំណត់ដោយគ.ល.ក.។

**មាត្រា៥៥ ._**

ប្រតិបត្តិករល្បែងពាណិជ្ជកម្មត្រូវមាននិងរក្សាកិច្ចបញ្ជិកាគណនេយ្យ អនុលោមតាមបទដ្ឋានគណនេយ្យជាធរមានដែលបង្ហាញអំពីប្រតិបត្តិការនិងស្ថានភាពហិរញ្ញវត្ថុ នៃប្រតិបត្តិការល្បែងពាណិជ្ជកម្មរបស់ខ្លួន។ កិច្ចបញ្ជិកាគណនេយ្យត្រូវធានាថា ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានធ្វើដោយត្រឹមត្រូវនិងតាមពេលវេលាកំណត់ និងបង្កលក្ខណៈដល់ការត្រួតពិនិត្យ ការស៊ើបអង្កេត និងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព។

**មាត្រា៥៦ ._**

ដោយមិនមានការប៉ះពាល់ដល់សវនកម្មផ្ទៃក្នុងជាប្រចាំ ប្រតិបត្តិករល្បែងពាណិជ្ជកម្មត្រូវធានាឱ្យមានសនវកម្មឯករាជ្យប្រចាំឆ្នាំលើរបាយការណ៍ហិរញ្ញវត្ថុនិងលើអនុលោមភាពនៃដំណើរការត្រួតពិនិត្យផ្ទៃក្នុងប្រកបតាមស្តង់ដាអប្បបរមានៃការត្រួតពិនិត្យផ្ទៃក្នុងដែលកំណត់ដោយគ.ល.ក. ហើយសវនករឯករាជ្យត្រូវមានការទទួលស្គាល់ពីគ.ល.ក. ដើម្បីធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម។ គ.ល.ក.អាចដាក់កាតព្វកិច្ចបន្ថែមចំពោះសវនករពាក់ព័ន្ធនឹងភារកិច្ចធ្វើសវនកម្មលើប្រតិបត្តិករល្បែងពាណិជ្ជកម្មតាមការចាំបាច់។ ចំណាយលើថ្លៃសេវានេះ គឺជាបន្ទុករបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម។

សវនកម្មឯករាជ្យដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវធ្វើឡើងស្របតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម រួមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ហើយប្រតិបត្តិករល្បែងពាណិជ្ជកម្មត្រូវផ្តល់របាយការណ៍សវនកម្មនោះទៅគ.ល.ក.។

**មាត្រា៥៧ ._**

ដោយមិនមានការប៉ះពាល់ដល់កាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងលិខិតប្រកាសចំណូលកាតព្វកិច្ចពីល្បែង ប្រតិបត្តិករល្បែងពាណិជ្ជកម្មត្រូវមានកាតព្វកិច្ចផ្តល់ជូនគ.ល.ក. នូវរបាយការណ៍និងព័ត៌មានដទៃទៀតប្រចាំគ្រាពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន តាមពេលវេលានិងបែបបទដែលកំណត់ដោយគ.ល.ក.។ ជាបន្ថែមលើរបាយការណ៍និងព័ត៌មានប្រចាំគ្រាដូចមានចែងខាងលើ គ.ល.ក.អាចតម្រូវឱ្យប្រតិបត្តិករល្បែងពាណិជ្ជកម្មផ្តល់ឯកសារ កំណត់ត្រា របាយការណ៍ និងព័ត៌មានដទៃទៀតតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ខ្លួនតាមការចាំបាច់។

**មាត្រា៥៨ ._**

ប្រតិបត្តិករកាស៊ីណូ ត្រូវមានកាតព្វកិច្ចផងដែរក្នុងការ៖

ក. ធានាឱ្យការប្រព្រឹត្តទៅរបស់កាស៊ីណូមានភាពប្រក្រតីនិងមិនរអាក់រអួល។

ខ. ធានាឱ្យមានប្រព័ន្ធអេឡិចត្រូនិកសុវត្ថិភាពនិងប្រព័ន្ធតាមដាន នៅក្នុងកាស៊ីណូនិងបរិវេណខាងក្រៅទ្វារចូលកាស៊ីណូ ហើយត្រូវមានក្រុមសន្តិសុខជំនាញឯកជនដែលមានសមត្ថភាពការពារសាធារណជន និងទ្រព្យសម្បត្តិនៅគ្រប់ពេលប្រតិបត្តិការកាស៊ីណូ។

គ. ធានាថា បុគ្គលឬគ្រឹះស្ថានពាក់ព័ន្ធនឹងប្រតិបត្តិការកាស៊ីណូ ដែលទទួលបានចំណូលដោយផ្ទាល់ ឬដោយប្រយោលពីកាស៊ីណូ ឬដែលបានផ្គត់ផ្គង់ទំនិញឬសេវាសម្រាប់ប្រតិបត្តិការកាស៊ីណូជាភាគីពាក់ព័ន្ធសមស្រប ហើយកិច្ចសន្យារបស់ប្រតិបត្តិករកាស៊ីណូជាមួយភាគីពាក់ព័ន្ធ ជាកិច្ចសន្យាត្រួតពិនិត្យសមស្រប។ និង

ឃ. ធានាថា បុគ្គលិកពិសេសរបស់ប្រតិបត្តិករកាស៊ីណូនិងកម្មករនិយោជិតរបស់កាស៊ីណូ ក្នុងពេលតែមួយ មិនមែនជាមន្ត្រីរាជការឬមន្ត្រីគ.ល.ក.។

ប្រតិបត្តិករកាស៊ីណូ ត្រូវផ្តល់ព័ត៌មានទៅគ.ល.ក.ជាបន្ទាន់តាមគ្រប់មធ្យោបាយ អំពីករណីដូចខាងក្រោម៖

ក. ហេតុការណ៍ឬកាលៈទេសៈដែលមានឥទ្ធិពលលើប្រតិបត្តិការកាស៊ីណូ ឬលើការគ្រប់គ្រងរបស់ប្រតិបត្តិករកាស៊ីណូ។

ខ. ហេតុការណ៍ឬកាលៈទេសៈដែលមានឥទ្ធិពលលើភាពជឿទុកចិត្តបាននិងសុចរិតភាពនៃភាគហ៊ុនិកមានគុណវុឌ្ឍិ ឬបុគ្គលិកពិសេស ឬភាពរឹងមាំ និងសមរម្យនៃស្ថានភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិករកាស៊ីណូនិងហេតុការណ៍សំខាន់ៗដទៃទៀត រួមទាំងហេតុការណ៍ទាំងឡាយ ដែលអាចបណ្តាលឱ្យប្រតិបត្តិករកាស៊ីណូនោះក្ស័យធន។

គ. វិវាទជាមួយប្រតិបត្តិករកាស៊ីណូឬបុគ្គលិកពិសេសនិងវិវាទរវាងភាគហ៊ុនិកមានគុណវុឌ្ឍិទាំងឡាយរបស់ប្រតិបត្តិករកាស៊ីណូ។ និង

ឃ. អាកប្បកិរិយាមិនសមរម្យឬអរិភាពប្រឆាំងនឹងប្រតិបត្តិករកាស៊ីណូ ដោយអ្នករាជការសាធារណៈ ទាំងកងកម្លាំងសន្តិសុខឬមន្ត្រីគ.ល.ក.។

កថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើ ក៏មានអានុភាពអនុវត្តចំពោះប្រតិបត្តិករល្បែងភ្នាល់ ល្បែងផ្សងសំណាង និងល្បែងពាណិជ្ជកម្មដទៃទៀតដែរ។

**មាត្រា៥៩ -**

គ.ល.ក.អាចធ្វើការណែនាំជាលាយលក្ខណ៍អក្សរទៅកាន់ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង និងប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត អំពីដំណើរការ ការត្រួតពិនិត្យ ឬការគ្រប់គ្រងប្រតិបត្តិការកាស៊ីណូ ឬប្រតិបត្តិការល្បែងដទៃទៀត ដែលការណែនាំនោះមិនត្រូវផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះ និងអាជ្ញាបណ្ណកាស៊ីណូ អាជ្ញាបណ្ណល្បែងភ្នាល់ អាជ្ញាបណ្ណល្បែងផ្សងសំណាង ឬអាជ្ញាបណ្ណល្បែងពាណិជ្ជកម្មដទៃទៀតឡើយ។ ការណែនាំខាងលើក៏រួមបញ្ចូលផងដែរនូវការណែនាំអំពីការអនុវត្ត ការកែប្រែ ការបញ្ឈប់ ឬការផ្អាកសកម្មភាពណាមួយពាក់ព័ន្ធនឹងប្រតិបត្តិការកាស៊ីណូ និង/ឬប្រតិបត្តិការល្បែងពាណិជ្ជកម្មដទៃទៀត។ ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង និងប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវអនុវត្តតាមការណែនាំរបស់គ.ល.ក. នៅពេលបានទទួលការណែនាំនោះ ឬនៅកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុងការណែនាំនោះ។

## ផ្នែកទី២
## ភ្ញៀវល្បែង

**មាត្រា៦០ -**

ភ្ញៀវល្បែង ជាអតិថិជនរបស់កាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀតមានសិទ្ធិដូចខាងក្រោម៖

ក. ទទួលបានប្រាក់ឈ្នះពេញលេញនៅពេលលេងឈ្នះល្បែងដោយសមស្របនិងត្រឹមត្រូវ។

ខ. អាចទទួលបានប្រាក់ឈ្នះជាសាច់ប្រាក់ឬតាមមធ្យោបាយណាមួយ ដែលអនុញ្ញាតដោយច្បាប់ឬបទប្បញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា។

គ. ទាមទារឬប្ដឹងទៅគ.ល.ក. ទាក់ទងនឹងការមិនទទួលបានប្រាក់ឈ្នះល្បែងពេញលេញ ឬសកម្មភាពបោកបន្លំរបស់ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង និងប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត។

ឃ. មានសិទ្ធិស្របច្បាប់ផ្សេងទៀត ដូចមានចែងនៅក្នុងវិធានល្បែងដែលកំណត់ដោយគ.ល.ក.។

ភ្ញៀវល្បែងត្រូវអនុវត្តខ្ជាប់ខ្ជួននូវបទប្បញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងភ្ញៀវល្បែងដែលកំណត់ដោយគ.ល.ក.។

ភ្ញៀវល្បែងមិនត្រូវ៖

ក. លេងភ្នាល់គ្នាដោយផ្ទាល់រវាងភ្ញៀវល្បែងនិងភ្ញៀវល្បែង នៅក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត។

ខ. ធ្វើសកម្មភាពណាមួយដែលប៉ះពាល់ដល់សណ្ដាប់ធ្នាប់និងសន្តិសុខសង្គម នៅក្នុងនិងជុំវិញបរិវេណនៃគ្រឹះស្ថានល្បែងពាណិជ្ជកម្ម។

## ផ្នែកទី៣
## ភាគីពាក់ព័ន្ធនិងកិច្ចសន្យាត្រួតពិនិត្យ

**មាត្រា៦១ -**

បុគ្គលដែលមិនមែនជាប្រតិបត្តិករល្បែងពាណិជ្ជកម្ម ហើយទទួលបានចំណូលដោយផ្ទាល់ឬដោយប្រយោលពីល្បែងពាណិជ្ជកម្ម ឬដែលផ្គត់ផ្គង់ទំនិញឬសេវាសម្រាប់ប្រតិបត្តិការល្បែងពាណិជ្ជកម្ម ត្រូវបានចាត់ទុក

ថាជាភាគីពាក់ព័ន្ធ។ ភាគីពាក់ព័ន្ធនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនិងទណ្ឌកម្មរដ្ឋបាល ឬពិន័យអន្តរការណ៍ពី គ.ល.ក. ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

គ.ល.ក.អាចចេញសេចក្តីណែនាំបន្ថែមតាមការចាំបាច់ ចំពោះការកំណត់ន័យទូទៅពីភាគីពាក់ព័ន្ធ ដូចបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើ ក្នុងគោលបំណងធ្វើចំណាត់ថ្នាក់ឬប្រភេទរបស់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិជាភាគីពាក់ព័ន្ធ សម្រាប់គោលបំណងនៃច្បាប់នេះ។

គ.ល.ក.អាចផ្តល់ការលើកលែងពីកាតព្វកិច្ចឬបញ្ញត្តិទាំងឡាយនៃផ្នែកនេះពាក់ព័ន្ធនឹងចំណាត់ថ្នាក់ ឬប្រភេទនៃភាគីពាក់ព័ន្ធតាមរយៈសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅប្រតិបត្តិករល្បែងពាណិជ្ជកម្ម។

**មាត្រា៦២ .-**

កិច្ចសន្យាឬកិច្ចសន្យាកែប្រែរបស់ប្រតិបត្តិករកាស៊ីណូជាមួយភាគីពាក់ព័ន្ធ ត្រូវចាត់ទុកថាជាកិច្ចសន្យាត្រួតពិនិត្យ ហើយកិច្ចសន្យាឬកិច្ចសន្យាកែប្រែនេះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គ.ល.ក. ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

គ.ល.ក.ត្រូវចេញសេចក្តីណែនាំបន្ថែមតាមការចាំបាច់ ចំពោះការកំណត់ន័យទូទៅនៃកិច្ចសន្យាត្រួតពិនិត្យដូចបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើ ក្នុងគោលបំណងកំណត់ចំណាត់ថ្នាក់ឬប្រភេទនៃកិច្ចសន្យាដែលមានលក្ខណសម្បត្តិជាកិច្ចសន្យាត្រួតពិនិត្យ សម្រាប់គោលបំណងនៃច្បាប់នេះ។ គ.ល.ក.ក៏ត្រូវកំណត់ផងដែរអំពីកម្រិតអប្បបរមានៃទំហំប្រតិបត្តិការ សម្រាប់ពិចារណាលើកិច្ចសន្យា ហើយកិច្ចសន្យា ដែលមានកម្រិតខ្ពស់ជាងកម្រិតអប្បបរមានោះ ជាកិច្ចសន្យាត្រួតពិនិត្យ។

## ផ្នែកទី៤
## ការត្រួតពិនិត្យប្រតិបត្តិករល្បែងពាណិជ្ជកម្មនិងភាគីពាក់ព័ន្ធ

**មាត្រា៦៣ .-**

គ.ល.ក.អាចចាត់ចែងធ្វើការស៊ើបអង្កេតតាមករណីជាក់ស្តែងនីមួយៗ លើភាពសមស្របរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មឬភាគីពាក់ព័ន្ធ ចំពោះប្រតិបត្តិការល្បែងពាណិជ្ជកម្ម ការទទួលចំណូលដោយផ្ទាល់ឬដោយប្រយោលពីល្បែងពាណិជ្ជកម្ម ឬការផ្គត់ផ្គង់ទំនិញ ឬសេវាសម្រាប់ប្រតិបត្តិការល្បែងពាណិជ្ជកម្ម។

ប្រតិបត្តិករល្បែងពាណិជ្ជកម្មឬភាគីពាក់ព័ន្ធ ត្រូវបានចាត់ទុកថាមានភាពសមស្រប ក្នុងករណីដែលបុគ្គលនោះមាន៖

ក. កេរ្តិ៍ឈ្មោះ ចរិតលក្ខណៈល្អ ស្មោះត្រង់ និងសុចរិត។

ខ. ស្ថានភាពហិរញ្ញវត្ថុរឹងមាំនិងស្ថិរភាពសមស្រប។ និង

គ. សមត្ថភាពនិងបទពិសោធធុរកិច្ចគ្រប់គ្រាន់ ដើម្បីដំណើរការអាជីវកម្មដោយជោគជ័យ នៅក្នុងកម្រិតមួយដែលនាំឱ្យដំណើរការល្បែងពាណិជ្ជកម្មរបស់ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ឬភាគីពាក់ព័ន្ធនោះ មិនអាចបង្កឱ្យប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់កេរ្តិ៍ឈ្មោះរបស់ព្រះរាជាណាចក្រកម្ពុជា ជាគោលដៅកម្សាន្ត[illegible]ជាតិ ឬទៅលើភាពជឿទុកចិត្តបាន ឬភាពសុចរិតនៃវិស័យល្បែងពាណិជ្ជកម្ម។

ក្នុងការវាយតម្លៃលើភាពសមស្របរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មឬភាគីពាក់ព័ន្ធ គ.ល.ក.ត្រូវពិចារណាផងដែរនូវលទ្ធផលនៃការវាយតម្លៃលើភាពសមស្របរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មឬភាគីពាក់ព័ន្ធនោះ ដែល[illegible]ដោយស្ថាប័នបរទេសដែលមានជំនាញនិងកេរ្តិ៍ឈ្មោះល្បីនៅក្នុងវិស័យនេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងការផ្តើមការស៊ើបអង្កេតអំពីភាពសមស្រប ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ និងអាស្រ័យលើការពិចារណាអំពីភាពសំខាន់ចាំបាច់ឬងាយស្រួលដើម្បីកំណត់ដោយពេញចិត្តលើភាពសមស្របរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មឬភាគីពាក់ព័ន្ធ គ.ល.ក.អាចៈ

ក. ផ្ញើឬជំរុញឱ្យធ្វើការស៊ើបអង្កេតនិងសួរចម្លើយ។

ខ. តម្រូវឱ្យប្រតិបត្តិករល្បែងពាណិជ្ជកម្មឬភាគីពាក់ព័ន្ធផ្តល់ឬរៀបចំ ឬតម្រូវឱ្យពួកគេជំរុញឱ្យនីតិបុគ្គលឬរូបវន្តបុគ្គលពាក់ព័ន្ធដទៃទៀតផ្តល់ឬរៀបចំព័ត៌មាននិងឯកសារចាំបាច់ផ្សេងៗ។

គ. តម្រូវឱ្យប្រតិបត្តិករល្បែងពាណិជ្ជកម្មឬភាគីពាក់ព័ន្ធ ជំរុញឱ្យនីតិបុគ្គលឬរូបវន្តបុគ្គលពាក់ព័ន្ធដទៃទៀត ផ្តល់សិទ្ធិឬយល់ព្រមឱ្យមន្ត្រីគ.ល.ក.អាចធ្វើការស៊ើបអង្កេត ឬទទួលព័ត៌មាននិងឯកសារចាំបាច់ផ្សេងៗ។ និង

ឃ. ប្រើសេវារបស់អ្នកផ្តល់ប្រឹក្សាខាងក្រៅនិងរបស់ជំនាញការ ដែលចំណាយនោះជាបន្ទុករបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មឬភាគីពាក់ព័ន្ធ។

ប្រសិនបើមានការពិនិត្យឃើញថា ប្រតិបត្តិករល្បែងពាណិជ្ជកម្មឬភាគីពាក់ព័ន្ធ អាចនឹងមិនមានភាពសមស្រប ហើយសកម្មភាពបច្ចុប្បន្នឬអនាគតរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មឬភាគីពាក់ព័ន្ធនោះអាចបង្កឱ្យប៉ះពាល់អវិជ្ជមានភ្លាមៗដល់កេរ្តិ៍ឈ្មោះរបស់ប្រទេសកម្ពុជាជាគោលដៅកម្សាន្តអន្តរជាតិ ឬទៅលើភាពជឿទុកចិត្តបានឬភាពសុចរិតនៃវិស័យល្បែងពាណិជ្ជកម្ម គ.ល.ក.អាចចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដោយកំណត់ថាៈ

ក. ចំពោះប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង និងប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត អាជ្ញាបណ្ណកាស៊ីណូ អាជ្ញាបណ្ណល្បែងភ្នាល់ អាជ្ញាបណ្ណល្បែងផ្សងសំណាង ឬអាជ្ញាបណ្ណល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវបានព្យួរស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ ឬ

ខ. ចំពោះភាគីពាក់ព័ន្ធ សកម្មភាពពាក់ព័ន្ធនឹងល្បែងពាណិជ្ជកម្ម ត្រូវបានផ្អាករហូតមានការកំណត់ជាថ្មីដោយគ.ល.ក.ថា ភាគីពាក់ព័ន្ធនោះមានភាពសមស្រប។

ក្នុងករណីមានការផ្អាកសកម្មភាពរបស់ភាគីពាក់ព័ន្ធ ដូចមានចែងក្នុងចំណុច(ខ)នៃកថាខណ្ឌទី៥ខាងលើ គ.ល.ក.ត្រូវចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅប្រតិបត្តិករល្បែងនីមួយៗ ដោយតម្រូវឱ្យពួកគេបញ្ឈប់ទំនាក់ទំនងអាជីវកម្មជាមួយភាគីពាក់ព័ន្ធដែលត្រូវបានផ្អាកនោះ រហូតដល់មានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាថ្មី អំពីការលុបចោលនូវការផ្អាកនោះ។

**មាត្រា៦៤ .-**

បន្ទាប់ពីគ.ល.ក.កំណត់ភាពមិនសមស្របរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម គ.ល.ក.អាចចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយៈ

ក. តម្រូវឱ្យប្រតិបត្តិករល្បែងពាណិជ្ជកម្ម ចាត់វិធានការកែលម្អភាពមិនសមស្របរបស់ខ្លួន ក្នុងអំឡុងពេលមួយសមស្របជាក់លាក់ ដូចបានកំណត់ក្នុងសេចក្តីជូនដំណឹង។ ឬ

ខ. ព្យួរអាជ្ញាបណ្ណកាស៊ីណូ អាជ្ញាបណ្ណល្បែងភ្នាល់ អាជ្ញាបណ្ណល្បែងផ្សងសំណាង ឬអាជ្ញាបណ្ណល្បែងពាណិជ្ជកម្មដទៃទៀត ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

បន្ទាប់ពីបានកំណត់ភាពមិនសមស្របរបស់ភាគីពាក់ព័ន្ធ គ.ល.ក.អាចចេញសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលអាចតម្រូវឱ្យភាគីពាក់ព័ន្ធ ក្នុងអំឡុងពេលមួយសមស្របជាក់លាក់៖

ក. ចាត់វិធានការកែលម្អតាមការចាំបាច់ ដើម្បីជំរុញឱ្យភាគីពាក់ព័ន្ធមានភាពសមស្រប។ ឬ

ខ. បញ្ចប់កិច្ចសន្យាត្រួតពិនិត្យទាំងអស់ ដែលភាគីពាក់ព័ន្ធនោះជាភាគីមួយឬជាអគ្គគាហកៈនៃកិច្ចសន្យានោះ។ និង

គ. បញ្ចប់ការចូលរួមក្នុងប្រតិបត្តិការល្បែងពាណិជ្ជកម្ម ការទទួលចំណូលដោយផ្ទាល់ឬដោយប្រយោលពីល្បែងពាណិជ្ជកម្ម ឬ ការផ្គត់ផ្គង់ទំនិញឬសេវាដល់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម។

ទោះបីជាកិច្ចសន្យាត្រួតពិនិត្យដែលភាគីពាក់ព័ន្ធជាភាគីមួយឬជាអគ្គគាហកៈនៃកិច្ចសន្យានោះ មិនត្រូវបានបញ្ចប់ដូចមានចែងក្នុងសេចក្ដីជូនដំណឹងនៃកថាខណ្ឌទី២ខាងលើក្ដី ក៏កិច្ចសន្យានោះត្រូវបានចាត់ទុកថាបានបញ្ចប់តាមពេលដែលបានកំណត់ក្នុងសេចក្ដីជូនដំណឹង។ ក្នុងករណីដែលកិច្ចសន្យាត្រួតពិនិត្យ ត្រូវបានបញ្ចប់អនុលោមតាមមាត្រានេះ កថាខណ្ឌទី៣នៃមាត្រា៦៦នៃច្បាប់នេះត្រូវយកមកអនុវត្ត។

**មាត្រា៦៥ ._**

ប្រតិបត្តិករល្បែងពាណិជ្ជកម្ម ដែលជាភាគីនៃកិច្ចសន្យាត្រួតពិនិត្យឬកិច្ចសន្យាកែប្រែ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគ.ល.ក. ក្នុងអំឡុងពេល១៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានចុះហត្ថលេខាលើកិច្ចសន្យាត្រួតពិនិត្យឬកិច្ចសន្យាកែប្រែនោះ ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងទាំងស្រុងនៃកិច្ចសន្យាត្រួតពិនិត្យឬកិច្ចសន្យាកែប្រែនោះ និងត្រូវបញ្ជាក់នូវចំណុចសំខាន់ៗនៃកិច្ចសន្យានោះតាមទម្រង់និងបែបបទកំណត់ដោយ គ.ល.ក.។

នៅពេលបានទទួលសេចក្ដីជូនដំណឹងតាមកថាខណ្ឌទី១ខាងលើនិងអាស្រ័យលើការពិចារណាអំពីភាពសំខាន់ចាំបាច់ឬងាយស្រួល ដើម្បីកំណត់ដោយពេញចិត្តលើភាពសមស្របនៃកិច្ចសន្យាត្រួតពិនិត្យ ឬកិច្ចសន្យាកែប្រែ គ.ល.ក.អាច៖

ក. ធ្វើឬជំរុញឱ្យធ្វើការស៊ើបអង្កេត ស្រាវជ្រាវ ឬសាកសួរ។

ខ. តម្រូវឱ្យប្រតិបត្តិករល្បែងពាណិជ្ជកម្មឬភាគីពាក់ព័ន្ធផ្ដល់ឬរៀបចំ ឬតម្រូវឱ្យពួកគេជំរុញឱ្យនីតិបុគ្គលឬរូបវន្តបុគ្គលពាក់ព័ន្ធដទៃទៀតផ្ដល់ឬរៀបចំព័ត៌មាននិងឯកសារចាំបាច់ផ្សេងៗ។

គ. តម្រូវឱ្យប្រតិបត្តិករល្បែងពាណិជ្ជកម្មឬភាគីពាក់ព័ន្ធ ជំរុញឱ្យនីតិបុគ្គលឬរូបវន្តបុគ្គលពាក់ព័ន្ធដទៃទៀតផ្ដល់សិទ្ធិឬយល់ព្រមឱ្យមន្ត្រីគ.ល.ក.អាចធ្វើការស៊ើបអង្កេត ឬការសាកសួរ ឬទទួលព័ត៌មាននិងឯកសារចាំបាច់ផ្សេងៗ។

ឃ. ប្រើសេវារបស់អ្នកផ្ដល់ប្រឹក្សាខាងក្រៅនិងរបស់ជំនាញការ ដែលចំណាយនោះជាបន្ទុករបស់ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ឬភាគីពាក់ព័ន្ធ។

កិច្ចសន្យាត្រួតពិនិត្យមួយត្រូវបានចាត់ទុកថា មិនមានភាពសមស្រប ប្រសិនបើ លក្ខខណ្ឌ ខ្លឹមសារ នៃកិច្ចសន្យា និងកាលៈទេសៈដទៃទៀត រួមទាំងភាពសមស្របនៃភាគីពាក់ព័ន្ធនីមួយៗ នៃកិច្ចសន្យានោះ អាចបង្កឱ្យប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរភ្លាមៗទៅលើភាពជឿទុកចិត្តបាន ភាពសុចរិត ភាពរឹងមាំនិងសមស្របនៃស្ថានភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ឬប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ឬស្ថិរភាពនៃប្រតិបត្តិការល្បែងពាណិជ្ជកម្មទាំងនោះ។

ប្រសិនបើមានការពិនិត្យឃើញថា កិច្ចសន្យាត្រួតពិនិត្យមួយអាចបង្កឱ្យប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរភ្លាមៗទៅលើភាពជឿទុកចិត្តបាន ភាពសុចរិត ភាពរឹងមាំ និងសមស្របនៃស្ថានភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម ឬស្ថិរភាពនៃប្រតិបត្តិការល្បែងពាណិជ្ជកម្ម ដែលអាចនាំឱ្យខូចខាតមិនអាចស្តារបានដល់កេរ្តិ៍ឈ្មោះរបស់ប្រទេសកម្ពុជា ជាគោលដៅកម្សាន្តអន្តរជាតិ គ.ល.ក.អាចចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម ឬភាគីពាក់ព័ន្ធនីមួយៗ ដោយតម្រូវឱ្យផ្អាកការអនុវត្តសិទ្ធិនិងកាតព្វកិច្ចនៅក្រោមកិច្ចសន្យាត្រួតពិនិត្យ រហូតដល់មានការកំណត់ជាថ្មីថា កិច្ចសន្យាមានភាពសមស្របឬមិនសមស្រប ហើយគ្មានភាគីណាមួយនៃកិច្ចសន្យាអាចផ្តល់អានុភាពចំពោះបញ្ញត្តិណាមួយនៃកិច្ចសន្យាក្នុងអំឡុងពេលនៃការផ្អាកនោះឡើយ។

**មាត្រា៦៦ ..**

បន្ទាប់ពីកំណត់បាននូវភាពមិនសមស្របនៃកិច្ចសន្យាត្រួតពិនិត្យ គ.ល.ក.អាចចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត និងភាគីពាក់ព័ន្ធ ដោយ៖

ក. តម្រូវឱ្យមានការកែលម្អកិច្ចសន្យាត្រួតពិនិត្យ ក្នុងអំឡុងពេលមួយសមស្របដូចបានកំណត់ក្នុងសេចក្តីជូនដំណឹង ដើម្បីជំរុញឱ្យកិច្ចសន្យាមានភាពសមស្របទៅតាមការពេញចិត្តរបស់គ.ល.ក.។ ឬ

ខ. តម្រូវឱ្យបញ្ចប់កិច្ចសន្យាក្នុងអំឡុងពេលមួយសមស្របដូចបានកំណត់ក្នុងសេចក្តីជូនដំណឹង។

ប្រសិនបើកិច្ចសន្យាមិនត្រូវបានកែប្រែឬបញ្ចប់ដូចបានតម្រូវក្នុងសេចក្តីជូនដំណឹង ស្របតាមកថាខណ្ឌខាងលើទេនោះ ក៏កិច្ចសន្យានោះ នៅតែត្រូវបានចាត់ទុកថា បានបញ្ចប់ក្នុងអំឡុងពេលដូចបានកំណត់ក្នុងសេចក្តីជូនដំណឹង។

ប្រសិនបើកិច្ចសន្យាត្រូវបានកែប្រែឬបញ្ចប់ ស្របតាមកថាខណ្ឌទី១និងទី២នៃមាត្រានេះ៖

ក. ភាគីនៃកិច្ចសន្យាមិនត្រូវមានសិទ្ធិឬកាតព្វកិច្ច ក្រោមកិច្ចសន្យាត្រួតពិនិត្យឬផ្នែកណាមួយនៃកិច្ចសន្យាកែប្រែ ដែលត្រូវបានបដិសេធចោលដោយមូលហេតុនៃការកែប្រែនោះទេ។

ខ. ការកែប្រែឬការបញ្ចប់កិច្ចសន្យានោះមិនត្រូវប៉ះពាល់ដល់សិទ្ធិដែលបានទទួលឬដល់ការទទួលខុសត្រូវរបស់ភាគីណាមួយនៃកិច្ចសន្យា ឬភាគីទទួលសិទ្ធិតាមរយៈកិច្ចសន្យាដែលបានកើតឡើងមុនពេលដែលការកែប្រែ ឬការបញ្ចប់នោះចូលជាធរមានឡើយ។

គ. ភាគីនៃកិច្ចសន្យាមិនមានការទទួលខុសត្រូវចំពោះការបំពានលើកិច្ចសន្យានោះ ដែលកើតឡើងដោយសារមូលហេតុតែមួយគត់នៃការកែប្រែឬការបញ្ចប់នោះឡើយ។ និង

ឃ. គ.ល.ក.មិនមានការទទួលខុសត្រូវណាមួយដោយមូលហេតុនៃការកែប្រែឬការបញ្ចប់កិច្ចសន្យាទេ។

## ជំពូកទី៦

## សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌

**មាត្រា៦៧ ..**

មន្ត្រីនគរបាលយុត្តិធម៌នៃអគ្គស្នងការដ្ឋាននគរបាលជាតិរបស់ក្រសួងមហាផ្ទៃមានសមត្ថកិច្ចពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

## ជំពូកទី៧
## ដែនកំណត់នៃការលេងល្បែង
## ផ្នែកទី១
## ការរឹតត្បិតពីការលេងល្បែង

**មាត្រា៦៨ ._**

ការចូលលេងល្បែងនៅក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្ម ត្រូវហាមឃាត់ដាច់ខាតចំពោះបុគ្គលដូចខាងក្រោម៖

ក. បុគ្គលដែលត្រូវបានចាត់ទុកថាមានវិបត្តិស្មារតី អសមត្ថភាពហិរញ្ញវត្ថុ ឬប្រកាសក្ស័យធនដោយតុលាការ។

ខ. បុគ្គលដែលស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងឬថ្នាំញៀន។

គ. បុគ្គលដែលយកមកជាមួយនូវអាវុធគ្រប់ប្រភេទ។

ឃ. បុគ្គលដែលមានអាយុក្រោម១៨ឆ្នាំ។ និង

ង. ប្រជាពលរដ្ឋខ្មែរទូទៅ ដោយរួមទាំងកងកម្លាំងប្រដាប់អាវុធ អ្នករាជការសាធារណៈ និងពលរដ្ឋទទួលអាណត្តិ ដោយការបោះឆ្នោត។

ការចូលលេងល្បែងនៅក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្ម ត្រូវបានហាមឃាត់ចំពោះកម្មករនិយោជិតរបស់ប្រតិបត្តិករកាស៊ីណូឬប្រតិបត្តិករល្បែងពាណិជ្ជកម្មនៃគ្រឹះស្ថានល្បែងពាណិជ្ជកម្មដែលពួកគេកំពុងបម្រើការនៅទីនោះ។

ការរឹតត្បិតពីការចូលលេងល្បែងនៅក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ មិនអនុវត្តលើល្បែងផ្សងសំណាងទេ។

**មាត្រា៦៩ ._**

ប្រតិបត្តិករល្បែងពាណិជ្ជកម្មក្រៅពីប្រតិបត្តិករល្បែងផ្សងសំណាង ត្រូវចាត់វិធានការសមស្របដើម្បីធានាថា បុគ្គលដែលត្រូវបានរឹតត្បិតពីការលេងល្បែង ដូចមានចែងក្នុងមាត្រា៦៨នៃច្បាប់នេះមិនចូលលេងល្បែងក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មរបស់ខ្លួន ដោយបំពានលើលក្ខខណ្ឌនៃការរឹតត្បិតឡើយ។

ប្រតិបត្តិករល្បែងពាណិជ្ជកម្មក្រៅពីប្រតិបត្តិករល្បែងផ្សងសំណាង ត្រូវមានយន្តការចាំបាច់ដើម្បីគ្រប់គ្រងការចូលលេងល្បែងឱ្យមានប្រសិទ្ធភាព រួមមាន៖

ក. រក្សាទុករបាយការណ៍បច្ចុប្បន្នកម្ម អំពីការរឹតត្បិតភ្ញៀវចូលលេងល្បែងក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មរបស់ខ្លួន។

ខ. រក្សាចំនួនភ្នាក់ងារសន្តិសុខគ្រប់គ្រាន់និងមានសមត្ថភាព ដើម្បីត្រួតពិនិត្យការចូលលេងល្បែងឱ្យមានប្រសិទ្ធភាព។

គ. បង្កើតយន្តការតាមដានគ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យការចូលលេងល្បែងឱ្យមានប្រសិទ្ធភាព។ និង

ឃ. ខណ្ឌចែកកន្លែងលេងល្បែងច្បាស់លាស់និងដាក់ស្លាកសញ្ញាសម្គាល់សមស្រប ដើម្បីបង្ហាញទីតាំងលេងល្បែងទាំងនោះ។

ប្រតិបត្តិករល្បែងពាណិជ្ជកម្មក្រៅពីប្រតិបត្តិករល្បែងផ្សងសំណាង ត្រូវ៖

ក. ប្រើភ្នាក់ងារសន្តិសុខតាមការចាំបាច់ ដើម្បីហាមឃាត់បុគ្គលដែលត្រូវបានរឹតត្បិតពីការចូលលេងល្បែងនៅក្នុងកាស៊ីណូរបស់ខ្លួនឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត និងបណ្តេញបុគ្គលទាំងនោះចេញពីទីតាំងលេងល្បែងឬធ្វើឱ្យបុគ្គលនោះចេញពីទីតាំងលេងល្បែងដោយមធ្យោបាយផ្សេងៗ។

ខ. ជូនដំណឹងដល់គ.ល.ក.ភ្លាមក្រោយពីកំណត់បានថា បុគ្គលដែលត្រូវបានរឹតត្បិតពីការលេងល្បែងបានលេងល្បែងឬមានបំណងចូលលេងល្បែងក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀតរបស់ខ្លួន។ និង

គ. បិទរាល់គណនីបញ្ញើនៅកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មរបស់បុគ្គលដែលត្រូវបានរឹតត្បិតពីការលេងល្បែង និងលុបឈ្មោះបុគ្គលនោះចេញពីបញ្ជីសមាជិកភ្ញៀវប្រចាំឬពីកម្មវិធីផ្តល់រង្វាន់ផ្សេងៗ។

**មាត្រា៧០.-**

បុគ្គលណាដែលបំពានលើបញ្ញត្តិអំពីការរឹតត្បិតពីការលេងល្បែង ត្រូវរងការរឹបអូសជាសម្បត្តិរដ្ឋនូវប្រាក់ឈ្នះពីល្បែង ដែលបាននិងកំពុងទូទាត់ឬនឹងត្រូវទូទាត់ ក្នុងអំឡុងពេលរឹតត្បិតនោះ។

## ផ្នែកទី២

## ការហាមឃាត់ការធ្វើសកម្មភាព

**មាត្រា៧១.-**

ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ឬប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវកំណត់អំពីលក្ខខណ្ឌ ដែលអនុញ្ញាតឱ្យភ្ញៀវល្បែងមានវត្តមាននៅក្នុង ឬចូលលេងល្បែងក្នុងកាស៊ីណូ ឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀតរបស់ខ្លួន។

នៅពេលមានការស្នើសុំប្រតិបត្តិករល្បែងពាណិជ្ជកម្មត្រូវផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់ដល់ភ្ញៀវល្បែងដែលមានបំណងលេងល្បែងនៅក្នុងកាស៊ីណូឬនៅក្នុងគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត អំពីលក្ខខណ្ឌនិងវិធាននៃការលេងល្បែងនៅទីនោះ។

ប្រតិបត្តិករល្បែងពាណិជ្ជកម្ម មានសិទ្ធិបដិសេធមិនឱ្យបុគ្គលណាម្នាក់ចូលក្នុងកាស៊ីណូឬក្នុងគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀតរបស់ខ្លួន ប្រសិនបើយល់ឃើញថាបុគ្គលនោះមិនបានបំពេញតាមលក្ខខណ្ឌរបស់កាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មនោះ។ ការហាមឃាត់នោះ មិនត្រូវអនុវត្តចំពោះមន្ត្រីគ.ល.ក. ក្នុងការបំពេញភារកិច្ចរបស់ខ្លួនឡើយ។

**មាត្រា៧២.-**

ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង និង/ឬប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀតត្រូវធានាថាមិនមានការប្រព្រឹត្តដោយបុគ្គលណាក្តី នៅក្នុងកាស៊ីណូឬក្នុងគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀតរបស់ខ្លួននូវសកម្មភាពដូចខាងក្រោម៖

ក. សកម្មភាពនានាដែលបង្កឱ្យមានអស្ថិរភាពនិងអសន្តិសុខក្នុងកិច្ចដំណើរការល្បែង។

ខ. ការលេងល្បែងដោយបន្លំឬឆបោក។

គ. សកម្មភាពស្រវឹងឬកាយវិការឥតសណ្តាប់ធ្នាប់ឬប្រចង់ប្រចាង។ និង

ឃ. ការបំពានលក្ខខណ្ឌនិងបទបញ្ជាផ្ទៃក្នុងរបស់កាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត។

ដោយមិនមានការប៉ះពាល់ដល់កថាខណ្ឌទី៤នៃមាត្រានេះ ប្រតិបត្តិករល្បែងពាណិជ្ជកម្ម មានកាតព្វកិច្ចប្រើកម្លាំងសន្តិសុខរបស់ខ្លួនតាមការចាំបាច់ ដើម្បីបណ្ដេញបុគ្គលដែលពាក់ព័ន្ធនឹងសកម្មភាពដូចបានរៀបរាប់ក្នុងកថាខណ្ឌទី១ខាងលើ ចេញពីកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀតនិងហាមឃាត់មិនឱ្យបុគ្គលនោះចូលកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មម្ដងទៀត ក្នុងរយៈពេល២៤ម៉ោង លើកលែងតែមានការណែនាំផ្សេងពីគ.ល.ក.។

ក្រោយពីបណ្ដេញបុគ្គលណាម្នាក់ចេញពីកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត តាមកថាខណ្ឌទី២ខាងលើភ្លាម ប្រតិបត្តិករល្បែងពាណិជ្ជកម្ម ត្រូវធ្វើការជូនដំណឹងដល់គ.ល.ក. ដោយផ្ដល់រាល់ព័ត៌មានទាំងអស់ទាក់ទងនឹងបុគ្គលដែលត្រូវបានបណ្ដេញចេញនិងបញ្ជាក់លម្អិតអំពីអង្គហេតុដែលខ្លួនសំអាង ដើម្បីបណ្ដេញបុគ្គលនោះចេញពីកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត។ គ.ល.ក.អាចចេញលិខិតហាមឃាត់អនុលោមតាមបញ្ញត្តិនៃមាត្រា៦៨នៃច្បាប់នេះ។

ប្រសិនបើមានការសង្ស័យថា បុគ្គលណាម្នាក់ជាប់ពាក់ព័ន្ធនឹងសកម្មភាពដូចបានកំណត់ ក្នុងចំណុច (ក)និង(ខ)នៃកថាខណ្ឌទី១ខាងលើ ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ឬប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវជូនដំណឹងដល់គ.ល.ក. ភ្លាម។ ក្នុងករណីចាំបាច់ ប្រតិបត្តិករល្បែងពាណិជ្ជកម្មទាំងនោះ អាចប្រើកម្លាំងសន្តិសុខរបស់ខ្លួន ដើម្បីចាត់វិធានការសមស្របនានានៅក្នុងគោលដៅធានាសន្តិសុខ សណ្ដាប់ធ្នាប់នៅកន្លែងនោះ ហើយត្រូវជូនដំណឹងភ្លាមទៅគ.ល.ក. ដើម្បីចាត់នីតិវិធីបន្តតាមផ្លូវច្បាប់។

នៅពេលមានការស្នើសុំអន្តរាគមន៍ដូចមានចែងក្នុងកថាខណ្ឌទី៣និងទី៤ខាងលើ មន្ត្រីនគរបាលយុត្តិធម៌នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ ត្រូវចាត់វិធានការសមស្រប ហើយអាចស្នើសុំការសហការពីមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធឬសុំគោលការណ៍ពីព្រះរាជអាជ្ញាតាមការចាំបាច់។

## ផ្នែកទី៣
## ការរឹតត្បិតការផ្សាយពាណិជ្ជកម្ម

**មាត្រា៧៣.-**

រាល់ការផ្សាយពាណិជ្ជកម្មអំពីល្បែងពាណិជ្ជកម្មត្រូវស្នើសុំការអនុញ្ញាតនិងយល់ព្រមពីគ.ល.ក.។

## ផ្នែកទី៤
## ការគ្រប់គ្រងលើវិធានល្បែង ឧបករណ៍ និង/ឬកម្មវិធីល្បែង

**មាត្រា៧៤.-**

គ.ល.ក.អាចផ្ដល់ការអនុម័តផ្សេងៗគ្នាទៅលើប្រភេទល្បែងនិងវិធានល្បែង អាស្រ័យលើការស្នើសុំរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម ភាពខុសគ្នានៃពេលវេលា ទីកន្លែង និងកាលៈទេសៈ។

ប្រតិបត្តិករល្បែងពាណិជ្ជកម្ម មិនត្រូវដំណើរការល្បែងណាមួយនៅក្នុងគ្រឹះស្ថានល្បែងពាណិជ្ជកម្មឡើយលុះត្រាតែ៖

ក. មានការយល់ព្រមជាមុនលើប្រភេទនៃល្បែងពីគ.ល.ក. ដែលការយល់ព្រមនេះនៅមានសុពលភាពជាធរមាន។

ខ. ល្បែងនោះត្រូវបានដំណើរការឬលេងស្របតាមរបៀបលេងនិងវិធានល្បែងដែលអនុម័តដោយគ.ល.ក.។ និង

គ. ល្បែងនោះត្រូវបានដំណើរការដោយបុគ្គលិកពិសេសដែលមានអាជ្ញាបណ្ណ។

**មាត្រា៧៥.-**

មុនផ្តល់ការយល់ព្រមលើឧបករណ៍និង/ឬកម្មវិធីល្បែង មន្ត្រីគ.ល.ក.អាចធ្វើការស៊ើបអង្កេតដើម្បីបញ្ជាក់ពីភាពសមស្របសម្រាប់ការប្រើប្រាស់នៅក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត ហើយរាល់ចំណាយនៃការស៊ើបអង្កេតជាបន្ទុករបស់អ្នកស្នើសុំ។ គ.ល.ក.អាចផ្តល់ការយល់ព្រមទៅលើឧបករណ៍ និង/ឬកម្មវិធីល្បែងជាក់លាក់មួយ ឬលើក្រុមនៃឧបករណ៍ល្បែងនិងអាចផ្តល់ការយល់ព្រមនោះ ដោយមានលក្ខខណ្ឌតាមការចាំបាច់។

បទប្បញ្ញត្តិដែលបង្កើតឡើងតាមច្បាប់នេះ អាចកំណត់ស្តង់ដានិង/ឬកម្មវិធីល្បែងចំពោះការផលិត ការដំឡើង ការនាំចូល ការចែកចាយ ឬការផ្គត់ផ្គង់ឧបករណ៍ និង/ឬកម្មវិធីល្បែង សម្រាប់ប្រើប្រាស់ នៅក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត។

ដោយមិនមានការប៉ះពាល់ដល់បញ្ញត្តិនៃច្បាប់ផ្សេងទៀត ការកាន់កាប់ឧបករណ៍ ឬ/និងល្បែងត្រូវបានចាត់ទុកថាមិនស្របច្បាប់ វៀរលែងតែឧបករណ៍ល្បែង និង/ឬកម្មវិធីនោះមានការបញ្ជាក់ថា បានទទួលការយល់ព្រមពីគ.ល.ក. សម្រាប់គ្រឹះស្ថានល្បែងពាណិជ្ជកម្មជាក់លាក់ណាមួយ។

**មាត្រា៧៦.-**

ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង និងប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវធានាថា៖

ក. ប្លង់នៃការរៀបចំបរិវេណផ្ទៃក្នុងនៃកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត រួមទាំងទីតាំងដាក់ម៉ាស៊ីនល្បែងសម្រាប់លេងជាដើម អនុលោមតាមការកំណត់របស់គ.ល.ក. ដែលអាចត្រូវបានធ្វើឡើងតាមការចាំបាច់។

ខ. ការកែប្រែសំខាន់ៗចំពោះប្លង់នៃការរៀបចំបរិវេណផ្ទៃក្នុងនៃកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវជូនដំណឹងជាមុនដល់គ.ល.ក.។

**មាត្រា៧៧.-**

កាក់ល្បែងរបស់គ្រឹះស្ថានល្បែងពាណិជ្ជកម្មនីមួយៗ ត្រូវសម្គាល់ដោយនិមិត្តសញ្ញាផ្ទាល់របស់គ្រឹះស្ថានល្បែងពាណិជ្ជកម្មនោះ សម្រាប់កំណត់អត្តសញ្ញាណនិងត្រូវបំពេញតាមលក្ខខណ្ឌបច្ចេកទេសដែលត្រូវបានកំណត់ដោយគ.ល.ក.។ គ្រឹះស្ថានល្បែងពាណិជ្ជកម្មមួយមិនអាចប្រើប្រាស់កាក់ល្បែងរបស់គ្រឹះស្ថានល្បែងពាណិជ្ជកម្មផ្សេងទៀតបានឡើយ។

**មាត្រា៧៨.-**

ប្រភេទនិងចំនួននៃឧបករណ៍ ឬ/និងកម្មវិធីល្បែង ដែលត្រូវផលិត ដំឡើង នាំចូល ចែកចាយ រួមទាំងនាំចេញជាថ្មី និងកម្ទេចចោល ត្រូវមានការអនុញ្ញាតពីគ.ល.ក. និងត្រូវអនុលោមតាមបញ្ញត្តិនៃច្បាប់នេះ។ គ.ល.ក.អាចចេញនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការចុះបញ្ជីលើប្រភេទឧបករណ៍ល្បែងមួយចំនួនដូចជាម៉ាស៊ីនស្លុតនិងម៉ាស៊ីនល្បែងពាណិជ្ជកម្មដទៃទៀត។ ឧបករណ៍ឬ/និងកម្មវិធីល្បែងដែលត្រូវបានអនុញ្ញាតឱ្យដំណើរការនៅក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវមានយថាប្រភេទអនុលោមតាមលិខិតបទដ្ឋានគតិយុត្តដែលកំណត់ដោយគ.ល.ក.។

**មាត្រា៧៩ ._**

ប្រតិបត្តិករល្បែងពាណិជ្ជកម្មអាចដំណើរការល្បែងសាកល្បងសម្រាប់ហ្វឹកហាត់និងណែនាំដល់បុគ្គលិកឬការធ្វើតេស្តម៉ាស៊ីនល្បែងឬឧបករណ៍ និង/ឬកម្មវិធីល្បែងបាន លុះត្រាតែមានការឯកភាពជាមុនពី គ.ល.ក.។

**មាត្រា៨០ ._**

គ.ល.ក.មានសិទ្ធិត្រួតពិនិត្យនូវបរិក្ខារ និងខ្សែអាត់សំឡេងនិងវីដេអូនៃឧបករណ៍សុវត្ថិភាពដែលបានបំពាក់នៅក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្ម។

ត្រូវហាមឃាត់ការដំឡើងម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ(អេ.ធី.អឹម)នៅក្នុងបរិវេណល្បែងនៃកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត។

## ជំពូកទី៨
## ចំណូលកាតព្វកិច្ចពីល្បែង កម្រៃអាជ្ញាបណ្ណ និងកាតព្វកិច្ចផ្សេងទៀត
### ផ្នែកទី១
### គោលការណ៍ទូទៅ

**មាត្រា៨១ ._**

ចំណូលពីល្បែង ត្រូវស្ថិតនៅក្រោមចំណូលកាតព្វកិច្ចពីល្បែង អនុលោមតាមមាត្រានេះ និងមាត្រា៨២នៃច្បាប់នេះ។ ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែង ផ្សងសំណាង និងប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវបង់ចំណូលកាតព្វកិច្ចពីល្បែង កម្រៃ និងសោហ៊ុយដូចខាងក្រោម៖

ក. ចំណូលកាតព្វកិច្ចពីល្បែងដូចមានចែងនៅក្នុងច្បាប់នេះឬនៅក្នុងបញ្ញត្តិពាក់ព័ន្ធ។

ខ. កម្រៃអាជ្ញាបណ្ណ ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា៣៥នៃច្បាប់នេះ។

គ. កម្រៃនៃការផ្ទេរសិទ្ធិកាន់កាប់អាជ្ញាបណ្ណ។

ឃ. កម្រៃឧបករណ៍កម្មវិធីល្បែង។ និង/ឬ

ង. សោហ៊ុយទម្រង់ការផ្សេងៗ ទៅតាមករណីជាក់ស្តែងនៃល្បែងពាណិជ្ជកម្ម។

កាតព្វកិច្ចបង់កម្រៃនិង/ឬសោហ៊ុយ ដូចមានចែងក្នុងចំណុច (ខ) (គ) (ឃ) និង(ង)នៃកថាខណ្ឌទី១ខាងលើ ក៏ត្រូវអនុវត្តផងដែរ ចំពោះអ្នកផលិត អ្នកដំឡើង អ្នកនាំចូល អ្នកលក់ អ្នកចែកចាយឧបករណ៍ កម្មវិធីល្បែង អ្នកជំរុញល្បែងពាណិជ្ជកម្ម និង/ឬភាគីពាក់ព័ន្ធដទៃទៀត។ លក្ខខណ្ឌនិងកាលបរិច្ឆេទនៃការបំពេញចំណូលកាតព្វកិច្ចពីល្បែងដូចមានចែងក្នុងចំណុច(ក)នៃកថាខណ្ឌទី១ខាងលើ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំពោះលក្ខខណ្ឌនិងកាលបរិច្ឆេទនៃការបង់កម្រៃនិង/ឬសោហ៊ុយដូចមានចែងក្នុងចំណុច (ខ) (គ) (ឃ) និង (ង)នៃកថាខណ្ឌទី១ខាងលើ ត្រូវកំណត់ដោយគ.ល.ក.។

ប្រតិបត្តិករល្បែងពាណិជ្ជកម្មនិងបុគ្គលពាក់ព័ន្ធមានកាតព្វកិច្ចផ្តល់ជូនគ.ល.ក. នូវលិខិតប្រកាសចំណូលកាតព្វកិច្ចពីល្បែងប្រចាំគ្រា តាមទម្រង់ និងបែបបទនិងពេលវេលាដែលកំណត់ដោយគ.ល.ក.។

ក្រៅពីចំណូលកាតព្វកិច្ចពីល្បែងដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនៃមាត្រានេះ កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ កម្មសិទ្ធិករកាស៊ីណូ ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករ

ល្បែងផ្សងសំណាង ប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀតនិង/ឬភាគីពាក់ព័ន្ធត្រូវគោរពកាតព្វកិច្ចសារពើពន្ធស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ លើកលែងតែមានការកំណត់ពិសេសក្នុងច្បាប់នេះ។

## ផ្នែកទី២
## ចំណូលកាតព្វកិច្ចពីល្បែង

**មាត្រា៨២ ._**

ប្រតិបត្តិករកាស៊ីណូ និង/ឬកម្មសិទ្ធិករកាស៊ីណូ និង/ឬកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណែ ត្រូវបំពេញចំណូលកាតព្វកិច្ចពីល្បែងប្រចាំគ្រាក្នុងអំឡុងពេលនៃការកាន់កាប់អាជ្ញាបណ្ណ។ អត្រានៃចំណូលកាតព្វកិច្ចពីល្បែង ត្រូវបានកំណត់ដូចខាងក្រោម៖

ក. កាស៊ីណូដែលស្ថិតនៅក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណែចំនួន៤(បួន)ភាគរយ ចំពោះភ្ញៀវល្បែងពិសេស និងចំនួន៧(ប្រាំពីរ)ភាគរយ ចំពោះភ្ញៀវល្បែងធម្មតា។

ខ. កាស៊ីណូដែលមិនស្ថិតនៅក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណែចំនួន៧(ប្រាំពីរ)ភាគរយ។

មូលដ្ឋាននៃការគណនាចំណូលកាតព្វកិច្ចពីល្បែង គឺចំណូលសរុបពីល្បែង។ ចំណូលសរុបពីល្បែងត្រូវបានគណនាដូចខាងក្រោម៖

ក. ចំណូលដុលដែលទទួលបានឬត្រូវទទួលបានពីល្បែងគ្រប់ប្រភេទ ដែលមានដំណើរការនៅក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត។

ខ. ដកចេញនូវប្រាក់ឈ្នះទាំងឡាយរបស់ភ្ញៀវល្បែង។

**មាត្រា៨៣ ._**

ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង និងប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវបំពេញចំណូលកាតព្វកិច្ចពីល្បែងប្រចាំគ្រាក្នុងអំឡុងពេលនៃការកាន់កាប់អាជ្ញាបណ្ណ។ ចំពោះអត្រាមូលដ្ឋាននៃការគណនានិងលក្ខខណ្ឌផ្សេងទៀតនៃចំណូលកាតព្វកិច្ចពីល្បែងនៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៨៤ ._**

ការបំពេញចំណូលកាតព្វកិច្ចពីល្បែង ត្រូវធ្វើឡើងដោយស្វ័យប្រកាសរបស់ប្រតិបត្តិករជារៀងរាល់ខែ យ៉ាងយូរត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ និងជាកម្មវត្ថុនៃការធ្វើសវនកម្ម។

## ជំពូកទី៩
## វិធានការផ្សះផ្សានិងការដោះស្រាយវិវាទ

**មាត្រា៨៥ ._**

ចំពោះវិវាទដែលពាក់ព័ន្ធនឹងសកម្មភាពល្បែងពាណិជ្ជកម្ម ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទនោះទៅគ.ល.ក.ដើម្បីផ្សះផ្សា លើកលែងតែបទល្មើសព្រហ្មទណ្ឌ។

**មាត្រា៨៦ ._**

ក្រោយពីទទួលបានពាក្យបណ្ដឹងហើយ គ.ល.ក.ត្រូវសាកសួរភាគីទាំងសងខាង ពីកម្មវត្ថុនៃវិវាទ រួចផ្ដើម [illegible] ផ្សះផ្សាភាគីនីមួយៗ ដោយយកច្បាប់ វិធាន និងបទប្បញ្ញត្តិផ្សេងៗជាមូលដ្ឋាន។ គ.ល.ក. [illegible]ត់ហេតុផ្សះផ្សានៃភាគីវិវាទតាមមាត្រានេះដោយមានជំនួយពីមន្ត្រីគ.ល.ក.។ កំណត់ហេតុផ្សះផ្សានេះ [illegible]ទនិងរក្សាទុកច្បាប់ដើមនៅគ.ល.ក.។

ការព្រមព្រៀងដែលបានធ្វើឡើងនៅចំពោះមុខគ.ល.ក. គឺជាការព្រមព្រៀងដែលមានអានុភាពជាលិខិតអនុវត្ត។ ក្នុងករណីការសម្រុះសម្រួល ផ្សះផ្សាមិនសះជាវវាងភាគីវិវាទ មន្ត្រីគ.ល.ក.ត្រូវធ្វើកំណត់ហេតុមិនសះជាជូនទៅភាគីវិវាទ ហើយភាគីវិវាទណាមួយដែលមិនសុខចិត្ត មានសិទ្ធិប្តឹងបន្តទៅវេទិកាមជ្ឈត្តកម្មឬទៅតុលាការមានសមត្ថកិច្ច។

នីតិវិធីនៃការផ្សះផ្សាវិវាទនឹងត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក.។

## ជំពូកទី១០

## ទណ្ឌកម្មរដ្ឋបាលនិងទោសប្បញ្ញត្តិ

## ផ្នែកទី១

## ទណ្ឌកម្មរដ្ឋបាល

### មាត្រា៨៧ .-

ទណ្ឌកម្មរដ្ឋបាលនៅក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរអាជ្ញាបណ្ណ និងការដកហូតអាជ្ញាបណ្ណ។

ការដាក់ទណ្ឌកម្មរដ្ឋបាលជាសមត្ថកិច្ចរបស់គ.ល.ក.។

បែបបទនិងនីតិវិធីក្នុងការដាក់ទណ្ឌកម្មរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក.។

ក្រៅពីអាជ្ញាបណ្ណកាស៊ីណូ ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរអាជ្ញាបណ្ណ និងការដកហូតអាជ្ញាបណ្ណត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក.។

### មាត្រា៨៨ .-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ចំពោះប្រតិបត្តិករកាស៊ីណូដែលប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើដូចខាងក្រោម៖

ក. ប្រព្រឹត្តផ្ទុយនឹងការណែនាំរបស់គ.ល.ក. ដូចមានចែងក្នុងមាត្រា៥៩នៃច្បាប់នេះ។

ខ. ការផ្សាយពាណិជ្ជកម្មអំពីល្បែងពាណិជ្ជកម្មដែលគ្មានការយល់ព្រមពីគ.ល.ក. ដូចមានចែងក្នុងមាត្រា៧៣នៃច្បាប់នេះ

គ. ដំណើរការល្បែងសាកល្បងសម្រាប់ហ្វឹកហាត់ និងណែនាំដល់បុគ្គលិក ឬធ្វើតេស្តម៉ាស៊ីនល្បែង ឬឧបករណ៍ និង/ឬកម្មវិធីល្បែងដោយគ្មានការឯកភាពជាមុនពីគ.ល.ក. ដូចមានចែងក្នុងមាត្រា៧៩នៃច្បាប់នេះ។

### មាត្រា៨៩ .-

ត្រូវព្យួរអាជ្ញាបណ្ណកាស៊ីណូចំពោះករណីដូចខាងក្រោម៖

ក. បុគ្គលិកពិសេសប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី២នៃមាត្រា៥៣នៃច្បាប់នេះ។

ខ. ប្រតិបត្តិករកាស៊ីណូប្រព្រឹត្តល្មើសនឹងមាត្រា៨០នៃច្បាប់នេះ។

គ. ប្រតិបត្តិករល្បែងពាណិជ្ជកម្មប្រព្រឹត្តល្មើសនឹងមាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ ចំណុចកនិងខនៃកថាខណ្ឌទី១នៃមាត្រា៦០ មាត្រា៧៦ ឬមាត្រា៧៧នៃច្បាប់នេះ។

ឃ. ប្រតិបត្តិករកាស៊ីណូប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី៥នៃមាត្រា៦៣នៃច្បាប់នេះ។

ង. ប្រតិបត្តិករកាស៊ីណូមិនគោរពតាមការព្រមានជាលាយលក្ខណ៍អក្សររបស់គ.ល.ក.។

**មាត្រា៩០.-**

ត្រូវដកហូតអាជ្ញាបណ្ណកាស៊ីណូ ចំពោះការប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើដូចខាងក្រោម៖

ក. ផ្ទេរអាជ្ញាបណ្ណល្បែងពាណិជ្ជកម្ម ឬប្រតិបត្តិការល្បែងពាណិជ្ជកម្មទាំងស្រុង ឬមួយផ្នែកតាមវិធី ឬរូបភាពណាក៏ដោយ ដោយមិនមានការអនុញ្ញាតពីគ.ល.ក.។

ខ. មិនបង់កាតព្វកិច្ចពន្ធដារ មិនបង់ចំណូលកាតព្វកិច្ចពីល្បែង កម្រៃអាជ្ញាបណ្ណ ឬកាតព្វកិច្ចហិរញ្ញវត្ថុដទៃទៀតក្នុងចំនួននិងតាមពេលកំណត់ ដូចមានចែងក្នុងមាត្រា៨២ មាត្រា៨៣ និងមាត្រា៨៤ នៃច្បាប់នេះ។

គ. ប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា៦៥នៃច្បាប់នេះ។

ឃ. បន្តប្រព្រឹត្ត ឬមិនកែលម្អអំពើល្មើសធ្ងន់ធ្ងរនឹងលក្ខខណ្ឌនៃអាជ្ញាបណ្ណ។

ង. នៅតែបន្តប្រព្រឹត្តអំពើល្មើសដែលមានចែងក្នុងមាត្រា៨៩នៃច្បាប់នេះ។

ច. នៅតែធ្វើប្រតិបត្តិការកាស៊ីណូក្នុងអំឡុងពេលព្យួរអាជ្ញាបណ្ណ។

**មាត្រា៩១.-**

បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលរបស់គ.ល.ក. ដូចមានចែងក្នុងជំពូកនេះ មានសិទ្ធិធ្វើបណ្តឹងទៅតុលាការ ក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃទទួលបានសេចក្តីសម្រេចនេះ។

## ផ្នែកទី២
## ការពិន័យអន្តរការណ៍

**មាត្រា៩២.-**

បទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់គ.ល.ក.។

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ សំណុំរឿងនៃបទល្មើសត្រូវបញ្ជូនទៅតុលាការដើម្បីចាត់ការតាមនីតិវិធី។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក.។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសក្នុងវិស័យគ្រប់គ្រងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍និងល្បែងពាណិជ្ជកម្ម។

អត្រានៃប្រាក់រង្វាន់ និងនីតិវិធីនៃការគ្រប់គ្រងនិងការប្រើប្រាស់ប្រាក់រង្វាន់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៣
## ទោសប្បញ្ញត្តិ

**មាត្រា៩៣.-**

ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ចំពោះបុគ្គលទាំងឡាយណាដែលប្រព្រឹត្តអំពើណាមួយក្នុងវិស័យគ្រប់គ្រងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ និងល្បែងពាណិជ្ជកម្មក្នុងចំណោមអំពើដូចខាងក្រោម៖

ក. អាជីវកម្មដំណើរការ ឬចូលរួមក្នុងប្រតិបត្តិការល្បែងពាណិជ្ជកម្មដោយគ្មានអាជ្ញាបណ្ណ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ខ. អំពើផលិត ដំឡើង នាំចូល លក់ ឬចែកចាយ ឬនាំចេញជាថ្មីឧបករណ៍ និង/ឬកម្មវិធីល្បែង ដោយគ្មានការអនុញ្ញាតពីគ.ល.ក.។

គ. អំពើក្លែងបន្លំឬប្រើប្រាស់លិខិតក្លែងពាក់ព័ន្ធនឹងវិស័យគ្រប់គ្រងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ និងល្បែងពាណិជ្ជកម្ម។

ឃ. អំពើក្លែងបន្លំឯកសារសាធារណៈឬប្រើប្រាស់ឯកសារសាធារណៈក្លែង ដែលចេញដោយរាជការសាធារណៈ ដោយអនុលោមតាមច្បាប់នេះ។

ង. អំពើឆបោក។

ច. អំពើរំលោភលើទំនុកចិត្ត។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**មាត្រា៩៤ ._**

ប្រតិបត្តិករល្បែងពាណិជ្ជកម្មដែលទទួលបានអាជ្ញាបណ្ណល្បែងពាណិជ្ជកម្មមុនច្បាប់នេះចូលជាធរមាន ត្រូវបំពេញលក្ខខណ្ឌទាំងឡាយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ រួមទាំងលក្ខខណ្ឌដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យនិងលិខិតបទដ្ឋានគតិយុត្តរបស់គ.ល.ក.។

កិច្ចព្រមព្រៀងដែលមានស្រាប់រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយប្រតិបត្តិករល្បែងពាណិជ្ជកម្ម ដែលបានធ្វើឡើងមុនច្បាប់នេះចូលជាធរមាន ត្រូវអនុវត្តបន្តពេញលេញ រហូតដល់កិច្ចព្រមព្រៀងទាំងនោះ ផុតសុពលភាព ដោយធានានូវគោលការណ៍ដូចខាងក្រោម៖

១. រាល់សិទ្ធិរបស់វិនិយោគិនដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាល ក្រោមកិច្ចព្រមព្រៀងទាំងនោះ ត្រូវបានគោរពយ៉ាងពេញលេញដោយគ.ល.ក. និងអ្នកពាក់ព័ន្ធ។

២. ការគ្រប់គ្រងគម្រោងវិនិយោគ ត្រូវអនុវត្តតាមលក្ខខណ្ឌនិងខ្លឹមសារនៃកិច្ចព្រមព្រៀងទាំងនោះ។ និង

៣. ការអនុវត្តច្បាប់នេះ ក្នុងលក្ខខណ្ឌណាមួយ នឹងមិនមានការប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិដែលទទួលបាននានារបស់វិនិយោគិន។

**មាត្រា៩៥ ._**

ចំណូលកាតព្វកិច្ចពីល្បែងសម្រាប់ប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង និងប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ចាប់ពីឆ្នាំសារពើពន្ធ ២០២១។

**មាត្រា៩៦ ._**

រចនាសម្ព័ន្ធ អភិបាលកិច្ច និងការគ្រប់គ្រងដែលមានស្រាប់ ត្រូវបន្តដំណើរការ ដើម្បីជួយគាំទ្រដល់ការបំពេញមុខងាររបស់អគ្គលេខាធិការដ្ឋាននៃគ.ល.ក. ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងត្រូវបញ្ចប់ជាស្ថាពរ នៅពេលដែលអគ្គលេខាធិការដ្ឋាននៃគ.ល.ក.បញ្ជាក់ថា ខ្លួនអាចដំណើរការការងារបានដោយខ្លួនឯង ដោយមិនលើសពី ១២ (ដប់ពីរ)ខែ គិតចាប់ពីថ្ងៃចូលជាធរមាននៃច្បាប់នេះ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៩៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ អាទិត្យ ១៤រោច ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០២០

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

នស.[illegible]

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ដលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

## សទ្ទានុក្រម

**វាក្យសព្ទគតិយុត្តដែលប្រើក្នុងច្បាប់នេះមានន័យដូចតទៅៈ**

**កម្មសិទ្ធិករកាស៊ីណូ** សំដៅដល់នីតិបុគ្គលដែលមានកម្មសិទ្ធិលើកាស៊ីណូមួយឬច្រើន សម្រាប់ប្រតិបត្តិការកាស៊ីណូ។

**កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍** សំដៅដល់នីតិបុគ្គលមានកម្មសិទ្ធិលើមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍មួយឬច្រើនដើម្បីដំណើរការនិងអភិវឌ្ឍល្បែងពាណិជ្ជកម្ម។

**ករណីប្រធានសក្តិ** សំដៅដល់ព្រឹត្តិការណ៍ឬកាលៈទេសៈដែលមិនអាចគ្រប់គ្រងបាន ហើយដែលមិនមែនជាកំហុសឬការធ្វេសប្រហែសរបស់ភាគីរងគ្រោះ និងជាព្រឹត្តិការណ៍ឬកាលៈទេសៈ ដែលភាគីនោះមិនអាចរារាំងបាន ទោះបីមានការខិតខំសមរម្យក្តី ដែលរួមមានៈ

- ក. កុបកម្ម សង្គ្រាម ការឈ្លានពាន សកម្មភាពរបស់កងទ័ពបរទេស សកម្មភាពវាយប្រយុទ្ធរបស់ក្រុមភេរវកម្ម សង្គ្រាមស៊ីវិល ការបះបោរ ការធ្វើរដ្ឋប្រហារ កុបកម្មរបស់ទាហាន ឬការដណ្តើមអំណាច ឬ/និងការដកហូត ឬកាន់កាប់ទីតាំងដោយអាជ្ញាធរមានសមត្ថកិច្ច។
- ខ. ការរាតត្បាតដោយមេរោគនិងឥទ្ធិពលនៃវិទ្យុសកម្មពីអាវុធនុយក្លេអ៊ែរ។
- គ. សម្ពាធរលកធាតុអាកាសដែលបង្កឡើងដោយយន្តហោះឬដោយឧបករណ៍មានល្បឿនលឿនខ្លាំង។
- ឃ. ការរញ្ជួយដី ទឹកជំនន់ អគ្គិភ័យ ឬគ្រោះមហន្តរាយធម្មជាតិផ្សេងទៀត តែមិនរាប់បញ្ចូលនូវលក្ខខណ្ឌអាកាសធាតុទេ ទោះបីមានកម្រិតធ្ងន់ធ្ងរក្តី។
- ង. បាតុកម្មឬវិវាទឧស្សាហកម្មកម្រិតជាតិ ឬបាតុកម្មឬវិវាទឧស្សាហកម្ម ដែលបង្កឡើងដោយកម្មករនិយោជិតដែលមិនមែនជានិយោជិតរបស់ភាគីរងគ្រោះ ឬរបស់អ្នកអនុវត្តកិច្ចព្រមព្រៀងបន្ត ឬរបស់អ្នកផ្គត់ផ្គង់នៃភាគីរងគ្រោះ ដែលសកម្មភាពនោះប៉ះពាល់ដល់ផ្នែកសំខាន់នៃការងារ ប៉ុន្តែមិនរាប់បញ្ចូលវិវាទឧស្សាហកម្មពាក់ព័ន្ធផ្ទាល់នឹងការអនុវត្តការងារនិងកិច្ចព្រមព្រៀងនោះឡើយ។

**កាក់ល្បែង** សំដៅដល់កាក់ឬបណ្ណដែលប្រើជំនួសរូបិយវត្ថុឬរូបិយបណ្ណពិតសម្រាប់គោលបំណងនៃការលេងល្បែង។

**ការផ្សាយពាណិជ្ជកម្មអំពីល្បែងពាណិជ្ជកម្ម** សំដៅលើសកម្មភាពដែលអាចទាក់ទាញចំណាប់អារម្មណ៍របស់សាធារណជនឬមជ្ឈដ្ឋានណាក្តី ដើម្បីឱ្យសាធារណជនឬមជ្ឈដ្ឋានទាំងនោះទៅលេងល្បែង ក្នុងកាស៊ីណូ ឬទៅគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀតញឹកញាប់ដើម្បីលេងល្បែង។

**ការលេងល្បែង** សំដៅដល់ការលេងល្បែងកាស៊ីណូ ល្បែងភ្នាល់ ល្បែងផ្សងសំណាង ឬល្បែងពាណិជ្ជកម្មដទៃទៀត ក្នុងគោលបំណងឈ្នះប្រាក់ឬវត្ថុដែលមានតម្លៃជាប្រាក់ ដោយផ្អែកទៅលើសំណាងសុទ្ធសាធឬលើសំណាងរួមជាមួយនឹងជំនាញ។

**កាស៊ីណូ** សំដៅដល់ទីតាំងនៃដំណើរការល្បែងពាណិជ្ជកម្មមួយចំនួន រួមមានផូកឃើ ប្លេកជេក បាការ៉ាត រ៉ូឡែត ស្លូតម៉ាស៊ីន និង/ឬល្បែងពាណិជ្ជកម្មដទៃទៀត ដោយមានអន្តរកម្មផ្ទាល់រវាងអ្នកដំណើរការល្បែងនិងអ្នកលេង ស្របតាមការកំណត់របស់គ.ល.ក.។

**កិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ** សំដៅដល់កិច្ចព្រមព្រៀងពាណិជ្ជកម្មដែលបង្កើតឡើងរវាងប្រតិបត្តិករកាស៊ីណូនិងកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬកម្មសិទ្ធិករកាស៊ីណូ ដែលតាមរយៈការទទួលបានអាជ្ញាប័ណ្ណកាស៊ីណូនេះ ប្រតិបត្តិករកាស៊ីណូ ត្រូវដំណើរការកាស៊ីណូនៅក្នុងបរិវេណ ឬផ្នែកណាមួយនៃ

មណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណ ឬកាស៊ីណូមួយឬច្រើនរបស់កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណ ឬកម្មសិទ្ធិករកាស៊ីណូនោះ និងត្រូវអនុលោមតាមខ្លឹមសារនិងលក្ខខណ្ឌដែលយល់ព្រមដោយគូភាគីនិងអនុម័តដោយគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា។

**កិច្ចព្រមព្រៀងអភិវឌ្ឍន៍កាស៊ីណូ** សំដៅដល់ការព្រមព្រៀងបង្កើតឡើងរវាងនីតិបុគ្គលឯកជនជាមួយគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជាដែលនៅក្រោមកិច្ចព្រមព្រៀងនោះ។ នីតិបុគ្គលឯកជនមានកាតព្វកិច្ចអភិវឌ្ឍកាស៊ីណូ ដោយផ្អែកលើខ្លឹមសារនិងលក្ខខណ្ឌដែលបានឯកភាពជាមួយគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា។

**កិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណ** សំដៅដល់ការព្រមព្រៀង បង្កើតឡើងរវាងនីតិបុគ្គលឯកជនជាមួយគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ដោយមានការឯកភាពពីរាជរដ្ឋាភិបាលដែលនៅក្រោមកិច្ចព្រមព្រៀងអភិវឌ្ឍន៍មណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណនោះ។ នីតិបុគ្គលឯកជនមានកាតព្វកិច្ចអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណ ដោយផ្អែកលើខ្លឹមសារនិងលក្ខខណ្ឌដែលបានឯកភាពជាមួយរាជរដ្ឋាភិបាល។

**កិច្ចសន្យាគ្រប់គ្រងកាស៊ីណូ** សំដៅដល់កិច្ចសន្យាល្បែងពាណិជ្ជកម្ម បង្កើតឡើងរវាងប្រតិបត្តិករកាស៊ីណូ និងអ្នកគ្រប់គ្រងកាស៊ីណូ ដែលក្នុងនោះ ប្រតិបត្តិករកាស៊ីណូនឹងផ្ទេរផ្នែកណាមួយឬទាំងអស់នៃកាតព្វកិច្ចរបស់ខ្លួននៅក្នុងកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ ទៅឱ្យអ្នកគ្រប់គ្រងកាស៊ីណូនោះ។

**កិច្ចសន្យាត្រួតពិនិត្យ** សំដៅដល់កិច្ចសន្យារបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មជាមួយភាគីពាក់ព័ន្ធ ទាក់ទងនឹងការផ្គត់ផ្គង់ទំនិញ ឬ សេវាមួយផ្នែកឬទាំងស្រុងសម្រាប់ប្រតិបត្តិការល្បែងពាណិជ្ជកម្ម ឬបញ្ហាផ្សេងទៀតដែលកំណត់ថា ជាបញ្ហាត្រូវស្ថិតក្រោមការត្រួតពិនិត្យសម្រាប់គោលបំណងនៃច្បាប់នេះ។

**គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា(គ.ល.ក.)** សំដៅដល់និយ័តករនិងបញ្ញត្តិករគ្រប់គ្រង និងត្រួតពិនិត្យ ព្រមទាំងប្រមូលចំណូលលើមណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណនិងល្បែងពាណិជ្ជកម្មដែលបង្កើតឡើងនៅក្នុងផ្នែកទី១ និងផ្នែកទី២ ជំពូកទី២ នៃច្បាប់នេះ។

**គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់** សំដៅដល់គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរដូចមានចែងក្នុងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**គ្រឹះស្ថានល្បែងពាណិជ្ជកម្ម** សំដៅដល់ទីកន្លែងឬទីតាំងនៃដំណើរការល្បែងពាណិជ្ជកម្ម រួមមាន ល្បែងកាស៊ីណូ ល្បែងភ្នាល់ ល្បែងផ្សងសំណាង ឬល្បែងពាណិជ្ជកម្មដទៃទៀត។

**ចំណូលសរុបពីល្បែង** សំដៅដល់ផលសរុបនៃ៖

ក. ចំណូលដុលដែលទទួលបានឬត្រូវទទួលបានពីល្បែងគ្រប់ប្រភេទដែលមានដំណើរការនៅក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត។

ខ. ដកចេញនូវប្រាក់ឈ្នះទាំងឡាយរបស់ភ្ញៀវល្បែង។

**តុល្បែង** សំដៅដល់តុសម្រាប់បម្រើដល់ការលេងល្បែងនៅក្នុងកាស៊ីណូ រួមមាន តុបាការ៉ាត់ ប្លេកជេក តុរ៉ូឡែត និងតុល្បែងពាណិជ្ជកម្មដទៃទៀត ដែលអនុញ្ញាតដោយគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**បុគ្គលិកពិសេស** សំដៅដល់បុគ្គលដែលបម្រើការក្នុងគ្រឹះស្ថានល្បែងពាណិជ្ជកម្មនិងមានសមត្ថកិច្ចជាអ្នកគ្រប់គ្រង ដែលមានសិទ្ធិធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងការចាត់ចែងលើប្រតិបត្តិការល្បែងពាណិជ្ជកម្ម ឬជាបុគ្គលដែលមានមុខងារនិងភារកិច្ចដូចមានចែងក្នុងផ្នែកទី៣ ជំពូកទី៤ នៃច្បាប់នេះ។

**បុគ្គលដែលត្រូវបានរឹតត្បិតពីការលេងល្បែង** សំដៅដល់បុគ្គលដែលមិនត្រូវបានអនុញ្ញាតឱ្យចូលឬមានវត្តមាននៅក្នុងបរិវេណកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត ដូចបានកំណត់ក្នុងផ្នែកទី១ ជំពូកទី៧ នៃច្បាប់នេះ។

**ប្រតិបត្តិករកាស៊ីណូ** សំដៅដល់នីតិបុគ្គលដែលកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ។

**ប្រតិបត្តិករល្បែងពាណិជ្ជកម្ម** សំដៅដល់នីតិបុគ្គល ដែលទទួលបានអាជ្ញាបណ្ណ សម្រាប់ប្រតិបត្តិការល្បែងពាណិជ្ជកម្ម។

**ប្រតិបត្តិការកាស៊ីណូ** សំដៅដល់ប្រតិបត្តិការពាក់ព័ន្ធនឹងសកម្មភាពល្បែងក្នុងកាស៊ីណូដូចខាងក្រោម៖

ក. កិច្ចដំណើរការល្បែងនៅក្នុងកាស៊ីណូ។

ខ. ការគ្រប់គ្រងនិងការត្រួតពិនិត្យកិច្ចដំណើរការល្បែងនៅក្នុងកាស៊ីណូ។

គ. ការរាប់ប្រាក់នៅក្នុងកាស៊ីណូនិងក្នុងប្រតិបត្តិការពាក់ព័ន្ធនឹងកាស៊ីណូ។

ឃ. នីតិវិធីគណនេយ្យនៅក្នុងកាស៊ីណូ និងក្នុងប្រតិបត្តិការពាក់ព័ន្ធនឹងកាស៊ីណូ។

ង. ការប្រើប្រាស់ឃ្លាំងនៅក្នុងបរិវេណកាស៊ីណូ។ និង

ច. ប្រតិបត្តិការផ្សេងទៀតដែលមានឥទ្ធិពលឬកើតឡើងពីសកម្មភាពនៅក្នុងកាស៊ីណូ។

**ភាគីពាក់ព័ន្ធ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមិនមែនជាប្រតិបត្តិករល្បែងពាណិជ្ជកម្ម និងមានចំណងទាក់ទងនៅក្នុងប្រតិបត្តិការល្បែងពាណិជ្ជកម្មដែលទទួលបានចំណូលដោយផ្ទាល់ ឬ ដោយប្រយោលពីល្បែងពាណិជ្ជកម្ម ឬដែលផ្គត់ផ្គង់ទំនិញ ឬសេវាសម្រាប់ប្រតិបត្តិការល្បែងពាណិជ្ជកម្ម។

**ភ្ញៀវល្បែង** សំដៅដល់បុគ្គលដែលមានសិទ្ធិចូលលេងល្បែងក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត ដែលទទួលបានការអនុញ្ញាតនៅក្រោមច្បាប់នេះ។ ភ្ញៀវល្បែង រួមមាន ភ្ញៀវល្បែងធម្មតា និងភ្ញៀវល្បែងពិសេស ដែលនឹងត្រូវកំណត់ដោយប្រកាសរបស់គ.ល.ក.។

**ភាគហ៊ុនមានគុណវុឌ្ឍិ** សំដៅដល់ការកាន់កាប់ភាគហ៊ុនដោយផ្ទាល់ឬដោយប្រយោលនៅក្នុងគ្រឹះស្ថានមួយក្នុងទំហំយ៉ាងហោច១០(ដប់)ភាគរយនៃភាគហ៊ុនសរុបរបស់គ្រឹះស្ថាននោះ។

**ភាគហ៊ុនិកមានគុណវុឌ្ឍិ** សំដៅដល់អ្នកកាន់កាប់ភាគហ៊ុនមានគុណវុឌ្ឍិ។

**ម៉ាស៊ីនល្បែង** សំដៅដល់ឧបករណ៍ ទោះមានលក្ខណៈជាមេកានិកឬអេឡិចត្រូនិកទាំងស្រុង ឬមួយផ្នែកក្តីដែលត្រូវបានផលិតឡើង ដើម្បីប្រើប្រាស់សម្រាប់បម្រើដល់ការលេងល្បែងផ្សងសំណាងសុទ្ធសាធ ឬល្បែងផ្សងសំណាងរួមជាមួយនឹងជំនាញនិងម៉ាស៊ីនដទៃទៀតតាមការកំណត់របស់គ.ល.ក.។

**មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍** សំដៅដល់ទីតាំងអភិវឌ្ឍន៍ដែលអនុញ្ញាតដោយរាជរដ្ឋាភិបាលដែលរួមបញ្ចូលជាអាទិ៍នូវទីតាំងបដិសណ្ឋារកិច្ច ភោជនីយដ្ឋាន ផ្សារទំនើប សណ្ឋាគារ មណ្ឌលកីឡា មណ្ឌលកម្សាន្តនិងទស្សនា និង/ឬមណ្ឌលសន្និបាតឬពិព័រណ៍ ហាងលក់ទំនិញរួចពន្ធ ហើយប្រតិបត្តិករកាស៊ីណូមួយឬអ្នកដំណើរការល្បែងពាណិជ្ជកម្មនៅលើទីតាំងអភិវឌ្ឍន៍នោះ។

**ល្បែងកាស៊ីណូ** សំដៅដល់ល្បែងពាណិជ្ជកម្មដែលត្រូវបានអនុញ្ញាតឱ្យដំណើរការនៅក្នុងកាស៊ីណូ ដូចជា ផៃហ្គោ ប្លេកជេក បាការ៉ាត រ៉ូឡែត ស្លុតម៉ាស៊ីន និង/ឬល្បែងផ្សេងទៀត ដោយប្រើសន្លឹកបៀរ

គ្រាប់ឡុកឡាក់ ឧបករណ៍មេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិក និង/ឬឧបករណ៍ និង/ឬកម្មវិធីល្បែងផ្សេងទៀត តាមការកំណត់របស់គ.ល.ក. ដោយមិនរាប់បញ្ចូលល្បែងភ្នាល់ ល្បែងផ្សងសំណាង និងល្បែងពាណិជ្ជកម្មដទៃទៀតទេ។

**ល្បែងផ្សងសំណាង** សំដៅដល់ល្បែងពាណិជ្ជកម្មដែលដំណើរការនៅក្រៅកាស៊ីណូដោយផ្អែកទៅលើសំណាងសុទ្ធសាធ ឬលើសំណាងមួយផ្នែក និងជំនាញរបស់ភ្ញៀវល្បែងមួយផ្នែក ដូចជា ល្បែងឆ្នោត ឡូតូ និង/ឬល្បែងផ្សងសំណាងផ្សេងទៀតដែលកំណត់ដោយគ.ល.ក.។

**ល្បែងពាណិជ្ជកម្ម** សំដៅដល់ល្បែងកាស៊ីណូ ល្បែងភ្នាល់ ល្បែងផ្សងសំណាង និង/ឬល្បែងពាណិជ្ជកម្មដទៃទៀត ដែលត្រូវបានធ្វើប្រតិបត្តិការដើម្បីគោលបំណងបង្កើត ប្រាក់ចំណេញ ឬដើម្បីគោលបំណងពាណិជ្ជកម្ម។ ល្បែងពាណិជ្ជកម្មដែលមិនពាក់ព័ន្ធដល់ការតម្រូវឱ្យទូទាត់បង់ប្រាក់ ឬវត្ថុដែលមានតម្លៃជាប្រាក់ដើម្បីមានលទ្ធភាព ឬមានសំណាងឈ្នះប្រាក់ ឬវត្ថុដែលមាន តម្លៃជាប្រាក់ មិនត្រូវចាត់ទុកជា "ល្បែងពាណិជ្ជកម្ម" សម្រាប់គោលបំណងនៃច្បាប់នេះទេ។

**ល្បែងភ្នាល់** សំដៅដល់ល្បែងពាណិជ្ជកម្មដែលផ្អែកលើការទស្សន៍ទាយលទ្ធផលនៃការប្រណាំង ការប្រកួត ឬព្រឹត្តិការណ៍ឥតព្រាងទុកណាមួយ។

**សិទ្ធិស្របច្បាប់ណាមួយលើទីតាំង** សំដៅដល់សិទ្ធិផលុបភោគ សិទ្ធិជួលអចិន្ត្រៃយ៍ ឬសិទ្ធិទាំងឡាយណាក្តី ដែលអនុញ្ញាតឱ្យម្ចាស់សិទ្ធិអាចអភិវឌ្ឍន៍និងមានកម្មសិទ្ធិលើមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬកាស៊ីណូនៅលើទីតាំងជាក់លាក់នោះ ក្នុងអំឡុងពេលជាក់លាក់ណាមួយនិងក្នុងលក្ខខណ្ឌដែលកំណត់ដោយគ.ល.ក.។

**អ្នកគ្រប់គ្រងកាស៊ីណូ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល ដែលទទួលកាតព្វកិច្ចមួយផ្នែកឬទាំងស្រុងនៅក្រោមកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ ពីប្រតិបត្តិករកាស៊ីណូឬបុគ្គលដែលត្រូវបានជ្រើសតាំងដោយគ.ល.ក. ដើម្បីគ្រប់គ្រងកាស៊ីណូមួយឬច្រើនដែលជាកម្មសិទ្ធិរបស់ប្រតិបត្តិករកាស៊ីណូ ដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ។

**អ្នកជំរុញល្បែងពាណិជ្ជកម្ម** សំដៅដល់នីតិបុគ្គលដែលមានធុរកិច្ចផ្តាច់មុខ ជាភ្នាក់ងាររបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មមួយឬច្រើន ដើម្បីទាក់ទាញភ្ញៀវល្បែងមកលេងល្បែងនៅក្នុងគ្រឹះស្ថានល្បែងពាណិជ្ជកម្មរបស់ប្រតិបត្តិករនោះ ដោយទទួលបាននូវកម្រៃជើងសាឬផលប្រយោជន៍ណាមួយ។

**អាជ្ញាបណ្ណកាស៊ីណូ** សំដៅដល់អាជ្ញាបណ្ណដែលផ្តល់ដោយគ.ល.ក. ពាក់ព័ន្ធនឹង "ល្បែងកាស៊ីណូ" ដែលដំណើរការនៅក្នុងកាស៊ីណូក្រោមផ្នែកទី២ ជំពូកទី៤នៃច្បាប់នេះ។

**អាជ្ញាបណ្ណបុគ្គលិកពិសេស** សំដៅដល់អាជ្ញាបណ្ណដែលផ្តល់ដោយគ.ល.ក. ក្រោមផ្នែកទី៣ ជំពូកទី៤នៃច្បាប់នេះ។

**ឧបករណ៍និង/ឬកម្មវិធីល្បែង** សំដៅដល់ឧបករណ៍និង/ឬកម្មវិធី ឬសម្ភារៈ រួមទាំងកាក់ល្បែង ដែលត្រូវបានប្រើប្រាស់សម្រាប់ដំណើរការល្បែងឬសកម្មភាពពាក់ព័ន្ធនឹងល្បែង ដែលរួមមាន តុល្បែង ម៉ាស៊ីនល្បែង ឬអេឡិចត្រូនិក សុវត្ថិភាព និងប្រព័ន្ធតាមដាន និងផ្នែក ឬគ្រឿងបន្លាស់សម្រាប់ឧបករណ៍ និង/ឬកម្មវិធី ឬប្រព័ន្ធទាំងនោះ និងឧបករណ៍និង/ឬកម្មវិធីល្បែង ឬសម្ភារៈដទៃទៀតតាមការកំណត់របស់គ.ល.ក.។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *